ខែ សីហា ឆ្នាំ 2017

213

សូមចូលទៅកាន់គេហទំព័រ www.itcity.com.kh ដើម្បីទាញយកទស្សនាវដ្ដីទីក្រុងពត៌មានវិទ្យាដោយឥតគិតថ្លៃ

# ទស្សនាវដ្ដី ទីក្រុង ពត៌មានវិទ្យា

IT MAGAZINE

*we live with technology*

IT CITY MAGAZINE



## ស្វែងយល់ពី

Acer Predator Helios 300,
Lenovo Idea Centre 520S,
HP ZBook 15 G4, HTC Desire 555
Samsung Galaxy J5 2017, Huawei Honor 6A

## តើគេអាចលួចយកគណនី Facebook របស់អ្នកបានយ៉ាងដូចម្ដេច?

## វិធីសាស្ត្រ៨យ៉ាង ស្រោចស្រង់ស្ថានការណ៍ត្រលប់មកវិញ ក្រោយការវាយប្រហារ Cyber Attack

## រថយន្ត Mercedes Benz X-Class



## វិធីងាយៗលេងហ្គេម Windows ជំនាន់មុនៗ លើ Windows 10

## ស្វែងយល់ពី Cloud Storage

ទំនាក់ទំនងផ្សាយពាណិជ្ជកម្ម 010 67 67 67 / 010 97 35 45

Herbal Health

# ថ្នាំបំប៉ន
# ផ្សំឡើងដោយ
# រុក្ខជាតិធម្មជាតិ ១០០%

## Jointcare

**មានប្រសិទ្ធិភាពខ្ពស់ ក្នុងការព្យាបាលៈ**

✓-រលាកសន្លាក់ឆ្អឹង

✓-ជម្ងឺប្រគ្រីវ

✓-កាត់បន្ថយការតានតឹង ខ្វល់ខ្វាយក្នុងអារម្មណ៍

✓-ការពារជម្ងឺកើតមុន និងរោគរលាកស្បែក

✓-រោគសន្លាក់ឆ្អឹងផ្សេងៗ




Herbal Health

ទីស្នាក់ការធំ រាជធានីភ្នំពេញ :
ផ្ទះលេខ 8AE0 ផ្លូវលេខ 156 សង្កាត់វាលវង់
ខណ្ឌ ៧មករា រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ 023 67 68 711 / 088 8651111 / 016 555 889



ដើម្បីសុវត្ថិភាពលោកអ្នក
- កាមេរ៉ាចាប់យករូបភាពច្បាស់ល្អ
- អាចមើលតាមទូរសព្ទពីចម្ងាយ
- ដំឡើងដោយជាងជំនាញ
មានបទពិសោធន៍ច្រើនឆ្នាំ
- ទទួលដំឡើងគ្រប់ខេត្ត ក្រុង
- តម្លៃថោកសមរម្យ
digital
Computer · Phone · Camera security
សូមអញ្ជើញមកកាន់ Digital Show Room :
ផ្ទះលេខ ៨ AEo ផ្លូវ ១៥៦ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
ទូរស័ព្ទ : 023 555 6 777

# មាតិកា

លេខទី២១៣ ខែសីហា ឆ្នាំ២០១៧
213 August 2017




## ឧបករណ៍អេឡិចត្រូនិចថ្មីៗ

14- ទូរទស្សន៍ Hisense H32M2600............
16- កាមេរ៉ា Canon EOS M6......................
18- នាឡិកា LG Watch Style.....................
19- នាឡិកា Garmin VivoSmart 3..............

## HardWare Review

20- Seagate Barracuda 4TB ផ្ដល់សុវត្ថិភាពកាន់តែខ្ពស់ និងប្រសើរបំផុត............
22- Scythe Mugen 5 PCGH Edition ដំណើរការដោយភាពឆ្លាតវៃ .........................

## Accessories

24- HP Elite 90W Thunderbolt 3 Dook....
25- Lenovo 500 Bluetooth Speaker.......
26- Marshall Moniter................................
26- UE Wonderboom.........................
27- Sony Xperia Touch............................
27- LG Tone Studio ................................

## Computer Review

52- HP ZBook 15 G4 ជាដៃគូការងារថ្មីរបស់អ្នក..............................
54- Acer Predator Helios 300 .................
56- Lenovo Idea Centre 520S-23IKU....

## ហ្គេមពេញនិយម

39- ហ្គេមអស្ចារ្យទាំង១០ ដែលពេញនិយមបំផុតលើប្រព័ន្ធប្រតិបត្តិការ iOS ................







DUAL USB
CAR CHARGER
30%
Discount
dexim
1.0A
2.1A
- Charge all iPhone and iPod models
- Charge all BlackBerry models
and other USB powered devices
in the car
- Blue LED light indicator
មានលក់នៅហាង Digital
#8AEo ផ្លូវលេខ១៥៦ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
Tel: 016 555 889, 023 555 6 777
Digital Cambodia
www.digital-cambodia.com

# មាតិកា

លេខទី២១៣ ខែសីហា ឆ្នាំ២០១៧
213 August 2017



ទំព័រ 46-50


## ម៉ូដែលទូរស័ព្ទថ្មីៗ

28- Galaxy Note 8 ..................................
29- Google Pixel 2..................................
30- Moto X4..........................................
31- Xiaomi REDMI 5...............................

## New Software

32- កម្មវិធីល្អបំផុតសម្រាប់ប្រព័ន្ធប្រតិបត្តិការ iOS ...............................
35- កម្មវិធីកុំព្យូទ័រថ្មីៗ .................................

## លក្ខណៈទូរស័ព្ទថ្មីៗ

46- Samsung J5 (2017) .........................
48- HUAWEI Honor 6A ..........................
50- HTC Desire 555..................................

## លក្ខណៈហ្គេមថ្មីៗ

42 - កំពូលអ្នកគ្រប់គ្រងជើងឯកប្រណាំងកង់ Pro Cycling Manager 2017......................
44 - MotoGP 2017 កំពូលជើងឯកប្រណាំងម៉ូតូ...........................

## Quick Study

61- វិធីងាយៗ លេងហ្គេមរបស់ Windows ជំនាន់មុន លើ Windows 10........................
63- វិធីបិទ Notification និង System Sounds នៅក្នុង Windows 10...................................

## Security

65- តើគេអាចលួចយកគណនីហ្វេសប៊ុករបស់អ្នកបានយ៉ាងដូចម្ដេច?.........................
66- តើអ្វីទៅជា Public Key Infrastructure..




ទំព័រ 42

AFFORDABLE RELIABLE INTERNET
CITY Link
YOUR OBVIOUS CHOICE

LEADING INTERNET SERVICE PROVIDER

# 1Mbps get 2Mbps
# 2Mbps get 4Mbps




023 220 112
www.citylink.com.kh

# មាតិកា

លេខទី២១៣ ខែសីហា ឆ្នាំ២០១៧
213 August 2017




ទំព័រ 80


## សំណួរមិត្តអ្នកអាន

69 - សំណួរ និងចម្លើយ

## ស្វែងយល់ពីរថយន្ត

74- Mercedes Benz Concept X-Class រថយន្ត Pickup ដ៏ទំនើបបំផុត រឹងមាំបំផុត........

## ព័ត៌មានជុំវិញបច្ចេកវិទ្យា

80- JAILBREAK the Game, Bong Pheak និងក្រសួងសាធារណការនិងដឹកជញ្ជូន ឈ្នះនូវ.....

82- ក្រុមហ៊ុន Apple ទទួលបានអាជ្ញាបណ្ណ សាកល្បងបណ្តាញ 5G...............................

83- គម្រោងបន្តរកលុយរយលានបន្ថែមទៀត របស់លោក Mark Zuckerberg...................

84- កុំព្យូទ័រ HP CHROMEBOOKS 11 ដាក់លក់ដំបូងបំផុតនៅកម្ពុជា.......................

86- ហេតុអ្វីបានជា Galaxy S8 ទទួលបានភាពល្បីល្បាញខ្លាំង?.......................................

## តារាងតម្លៃ

88- តារាងតម្លៃទូរស័ព្ទ

94- តារាងតម្លៃកុំព្យូទ័រ និងគ្រឿងបន្លាស់




ទំព័រ 69

**ចាងហ្វាងការផ្សាយ**
អនុបណ្ឌិត : ប៉ុល ច័ន្ទវីរៈ
**នាយករងការផ្សាយ**
លោក : ឆាន សុជា
**ប្រធានផ្នែកព័ត៌មាន និងនិពន្ធ**
កញ្ញា : ប៉ោក លក្ខិណា
**ផ្នែកព័ត៌មាន និងនិពន្ធ**
លោក : ម៉ម សុវណ្ណថា
កញ្ញា : សៀង ចាន់ថូ
**ផ្នែករចនាទំព័រ**
លោក : ស្វាយ សេរីវុត្ថា
លោក : រស់ ចំរើន
**ប្រធានផ្នែកទីផ្សារ**
លោក : ទិត្យ ណារិទ្ធ
**ផ្នែកគេហទំព័រ**
កញ្ញា : ប៉ោក លក្ខិណា
លោក : ម៉ម សុវណ្ណថា

អាសយដ្ឋាន : ផ្ទះលេខ ៨ AEo
ផ្លូវលេខ ១៥៦ សង្កាត់វាលវង់
ខណ្ឌ ៧មករា រាជធានីភ្នំពេញ

**ទំនាក់ទំនងផ្សាយពាណិជ្ជកម្ម**
010 67 67 67
010 97 35 45
018 9333337

ទំព័រ 74



# បច្ចេកវិទ្យាចុងក្រោយក្នុងការព្រីន
# CONFIDENTIAL CODE



ផ្ញើលេខកូដទៅកាន់អតិថិជនរបស់អ្នកនៅក្នុងវិធីដ៏មានសុវត្ថិភាព **100%** ជាមួយនឹងការច្នៃប្រឌិតថ្មីបំផុតរបស់យើង។

បច្ចេកវិទ្យាចាស់



បច្ចេកវិទ្យាថ្មីចុងក្រោយ



### ប្រសិទ្ធភាព
សាមញ្ញ ងាយស្រួលអនុវត្តន៍
និងងាយស្រួលប្រើប្រាស់

### ភាពអាចកំបាំង
ព័ត៌មានសម្ងាត់អានបានតែម្តងប៉ុណ្ណោះ
មិនអាចត្រឡប់ម្តងទៀតបានទេ

### សុវត្ថិភាព
ព័ត៌មានធានាសុវត្ថិភាពទាំងស្រុង
ក្នុងអំឡុងពេល និងបន្ទាប់ពីការបោះពុម្ព



ធនាគារអឺរ៉ុប និងក្រុមហ៊ុនធានារ៉ាប់រងជាច្រើនកំពុងប្រើបច្ចេកវិទ្យារបស់យើង:

#8AE0, Sangkat Veal Vong, Khan 7 Makara,
Phnom Penh City, Cambodia
Tel: (855) 16 555 889 / 018 333337


EMAXX™ 4G
Internet - WIMAX - Fiber Optics - Telecom Services
4G SPEED
AT YOUR
FINGERTIPS
No. 99, Preah Norodom,
Level 1, Phnom Penh
info@emaxxtelecom.com
www.emaxxtelecom.com
023 999 818
YOUR INTERNET
SERVICE PROVIDER



NIPTICT
In Cooperate with
សឺវីងវេប
Serving Web
ENROLLMENT START!
30% DISCOUNT
Courses Offer:
Professional Certificate in
Web & Graphic Design 270$
Networking 120$
Mobile App Development 150$
Programming 75$
015 / 077 / 090 335-877
023-885-510 / 012/015-986-101
ict@niptict.edu.kh / info@servingweb.com




it ទីក្រុងព័ត៌មានវិទ្យា
IT CITY MAGAZINE
MAGAZINE We Live With Technology
Magazine Store
ADS HERE 010 676767
ចំណេះដឹង
ភាពជោគជ័យ
ស្ថិតនៅក្នុងដៃរបស់លោកអ្នក !
Available on the App Store
ANDROID APP ON Google play


MEKONGNET
CONNECTING YOU ALL
100+ Gbps
SPEED UP TO
Speed Up
YOUR BUSINESS
MOVE TO US
023 22 66 22
www.mekongnet.com.kh sales@corp.mekongnet.com.kh




# 1.5 MB SPEED

## UPLOAD 3MB

# 25$

**GET ONE MONTH FREE**

Wicam — The best connection

#113, St. 271, Sangkat Boeung Salang, Khan Toul Kok, Phnom Penh.
Telephone: (855) 23 22 40 40 / (855) 23 22 25 35
Fax: (855) 023 22 25 26
E-mail:info@wicam.com.kh / sales@wicam.com.kh
facebook.com/wicamcorporate
twitter.com/wicamisp

# Hisense H32M2600 បង្ហាញភាពទាក់ទាញមិនចាញ់ទូរទស្សន៍ធំៗប៉ុន្មាននោះទេ




បច្ចុប្បន្ននេះ ទីផ្សារនៃការលក់ស្មាតធីវីគឺកំពុងតែវិវត្តន៍កាន់តែជឿនលឿនឡើងៗពីមួយថ្ងៃទៅមួយថ្ងៃហើយ ពោលគឺមិនថាស្មាតធីវីណាឡើយ ឱ្យតែមានមុខងារកាន់តែទំនើប នោះអេក្រង់របស់វាក៏កាន់តែធំដែរ។ តើមានអ្វីប្លែកបានជា Hisense ផ្ដល់ជូនត្រឹម 32 អ៊ីញទៅវិញ។ មានមូលហេតុជាច្រើនដែល Hisense បានផ្ដល់ជូនដូចនេះ ពីព្រោះថារាល់អ្នកទិញទាំងអស់គឺមិនប្រាកដថាមានបន្ទប់ទទួលភ្ញៀវធំទាំងអស់នោះទេ ហើយពេលខ្លះអ្នកទាំងនោះអាចនឹងមិនមានលទ្ធភាពគ្រប់គ្រាន់ដើម្បីទិញទូរទស្សន៍ធំៗទាំងនោះក៏ថាបាន ហេតុដូចនេះទើប Hisense H32M2600 32 អ៊ីញនេះក្លាយជាជម្រើសដ៏ស័កសមសម្រាប់ពួកគេ។ សម្រាប់រូបរាងឌីហ្សាញរបស់ Hisense H32M2600 គឺពិតជាស្រស់ស្អាត និងទំនើបមែនទែន ដោយក្នុងនោះវាបានប្រើប្រាស់ជ័រផ្លាស្ទិចសម្រាប់បង្កើតជារាងពៅ និងប្រើប្រាស់លោហៈធាតុរលោងជាគែមដាក់ព័ទ្ធជុំវិញផ្ទៃអេក្រង់ទាំងមូល ហើយបានដាក់ឡូហ្គូ Hisense នៅផ្នែកខាងក្រោមនៃអេក្រង់ផងដែរ មើលទៅពិតជាទាន់សម័យមិនចាញ់ទូរទស្សន៍ធំៗប៉ុន្មាននោះទេ។ អ្វីដែលធ្វើឱ្យអ្នកភ្ញាក់ផ្អើល ហើយទទួលបានអារម្មណ៍ប្លែកនោះគឺផ្ទាំងបង្ហាញរបស់វា ដោយស្មាតធីវីមួយនេះបានផ្ដល់នូវអ្វីដែលអ្នកត្រូវការតែម្ដង។






បើនិយាយឱ្យចំទៅគឺវាអាចបង្ហាញបាន 1080p នៃ Resolution Full HD ហើយថែមទាំងអាចផ្តល់ពន្លឺបានច្បាស់គ្រប់ទីកន្លែងនៅលើអេក្រង់ និងមានប្រើប្រាស់ពណ៌ស្រស់ស្អាតដូចទៅនឹងពណ៌ពីធម្មជាតិអ៊ីចឹងដែរ។ ចំណែកឯប្រព័ន្ធសំឡេងរបស់វាវិញគឺអាចផ្តល់សំឡេងមិនអន់នោះទេ ជាការពិតនោះគឺវាផ្តល់សំឡេងបានឮច្បាស់ពាសពេញបន្ទប់អ្នក ហើយមិនមានសំឡេងបន្លឺមករំខានរញ៉េរញ៉ៃនោះឡើយ។ សូមរីករាយជាមួយនឹងកម្មវិធីកម្សាន្តដ៏សម្បូរបែប ដើម្បីនាំអ្នកទៅកាន់ពិភពកម្សាន្តដែលអ្នកចង់កម្សាន្តបានភ្លាមៗ ហើយប្រសិនបើអ្នកចង់ភ្ជាប់ទៅកាន់ពិភពលោក Hisense H32M2600 អាចធ្វើបានយ៉ាងសាមញ្ញបំផុង ពីព្រោះនៅខាងក្នុងទូរទស្សន៍នេះគឺបានភ្ជាប់មកជាមួយនឹងប្រព័ន្ធ WIFI រួចជាស្រេចទៅហើយសម្រាប់បើក Browser ឬកម្មវិធីបណ្តាញសង្គមផ្សេងៗ។ បើអ្នកកំពុងតែស្វែងរកទូរទស្សន៍ដែលមានទំហំអេក្រង់ 32 អ៊ីញនោះ Hisense H32M2600 គឺតែជាស្មាតធីវីដំបូងដែលអ្នកគួរគិតដល់មុនគេ៕

## លក្ខណៈទូទៅ

| | |
|---|---|
| Front-cover Colour | Black |
| Panel Resolution | 1366 x 768 |
| Diagonal Screen Size | 32˝ |
| Dynamic Contrast | 2400 |
| Common Interface (CI) | Yes |
| Digital Reception (DVB) | DVB-T2/T/C/S2/S |
| HDMI Input | 3 |
| USB | 2 |
| Annual Consumption (kWh) | 44 |
| Power Supply | 220V-240V 50Hz |






# Canon EOS M6

## មានប្រើប្រាស់ប្រព័ន្ធទប់លំនឹងថ្មី ដើម្បីថតរូបបានកាន់តែប្រសើរ



សូមណែនាំនូវកាមេរ៉ាស៊េរីថ្មី EOS M6 របស់ Canon ដែលវាជាកាមេរ៉ាមួយដ៏ទំនើប មានប្រើប្រាស់ទៅដោយ Hardware ថ្មីៗកំពុងតែពេញនិយមបំផុតនៅលើទីផ្សារ ហើយមានមុខងារដ៏គួរឱ្យទាក់ទាញផងដែរ។ ជាមួយនឹងបច្ចេកវិទ្យាដ៏ទំនើបដើម្បីផ្តល់ជូនរូបភាពដ៏មានគុណភាពនោះ គឺបានធ្វើឱ្យវាក្លាយជាកាមេរ៉ាចល័តដែលកំពុងពេញនិយមប្រើប្រាស់បំផុតនាពេលបច្ចុប្បន្ននេះ។ ជាការពិតណាស់គឺ EOS M6 បានដាក់ឱ្យប្រើប្រាស់នូវ Sensor សម្រាប់ថតរូបប្រភេទ APS-C ទំហំ 24.2 មេហ្គាភីចសែលដែលវាអាចផ្តល់រូបថតដែលមាន Resolution ខ្ពស់ ហើយចំណែកឯការថតវីដេអូ Full HD វិញគឺជារឿងដ៏សាមញ្ញមួយប៉ុណ្ណោះសម្រាប់វា។ ទន្ទឹមនឹងនេះដែរ វាក៏បានប្រើប្រាស់នូវ Sensor សម្រាប់ចាប់យករូបប្រភេទ Dual Pixel CMOS AF ដែលអាចផ្តល់ល្បឿនលឿននៅពេលអ្នកកំពុងថត និងអាចដំណើរការបានយ៉ាងត្រឹមត្រូវថែមទៀតផង។ ខណៈពេលដែលអ្នកកំពុងតែកាន់កាមេរ៉ាថតរូបភាពរំញ័រគឺតែងតែកើតមានឡើង ទោះបីជាអ្នកព្យាយាមទប់លំនឹងយ៉ាងណាក៏ចៀសមិនផុតពី




បញ្ហានេះដែរ ប៉ុន្តែសម្រាប់ EOS M6 វិញគឺអាចផ្តល់រូបភាព ឬវីដេអូបានប្រកបដោយគុណភាពខ្ពស់ មិនធ្វើឱ្យរូបភាពព្រិលនៅពេលដែលរាងកាយរបស់វារលាក់នោះឡើយ នេះគឺដោយសារតែវាបានបំពាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធទប់លំនឹង (5-axis Digital Image Stabilization) ដ៏មានស្តង់ដារបំផុតសម្រាប់ប្រើប្រាស់ជាមួយវា។ EOS M6 គឺត្រូវបានឌីហ្សាញឡើងជាមួយនឹងប្រព័ន្ធ Wi-Fi ដែលផ្តល់ល្បឿនលឿន ហើយមានភាពងាយស្រួលក្នុងការភ្ជាប់ប្រើប្រាស់ថែមទៀតផង។ អ្វីដែលគួរឱ្យស្ញប់ស្ញែងបន្ថែមទៀតនោះគឺវាអាចភ្ជាប់ជា មួយនឹងកាមេរ៉ាដទៃទៀតក៏បានដែរ ដើម្បីធ្វើការចែករំលែកភាពសប្បាយរីករាយទៅវិញទៅមកនោះ។ ដើម្បីផ្តល់ភាពងាយស្រួលសម្រាប់បង្ហាញ ឬពិនិត្យមើល Files ដែលអ្នកបានថតរួចនោះគឺ Canon បាន Built-in មកជាមួយស្រាប់ជាមួយនឹងបន្ទះអេក្រង់ដែលមាន Resolution ខ្ពស់ប្រភេទ LCD ទំហំ 3.0 អ៊ីញ ដើម្បីផ្តល់ភាពងាយស្រួលក្នុងការគ្រប់គ្រងប្រើប្រាស់ អ្វីដែលពិសេសនោះគឺអ្នកអាចបត់បង្វិលវាបាន 180 ដឺក្រេងណោះទៅផ្នែកខាងលើ និងអាចទាញបត់ចុះក្រោមបាន 45 ដឺក្រេផងដែរ ហេតុនេះទោះបីជាអ្នកដាក់កាមេរ៉ានេះថតនៅទីតាំងណា ក៏អ្នកអាចពិនិត្យមើលទិដ្ឋភាពបានច្បាស់មុនពេលដែលអ្នកចុចថតបានដែរ៕




## លក្ខណៈពិសេស

| | |
|---|---|
| Body type | Rangefinder-style mirrorless |
| Max resolution | 6000 x 4000 |
| Effective pixels | 24 megapixels |
| Sensor size | APS-C (22.3 x 14.9 mm) |
| Sensor type | CMOS |
| ISO | Auto, 100-25600 |
| Lens mount | Canon EF-M |
| Focal length mult. | 1.6× |
| Articulated LCD | Tilting |
| Screen size | 3 |
| Screen dots | 1,040,000 |
| Max shutter speed | 1/4000 sec |
| Format | MPEG-4, H.264 |
| Storage types | SD/SDHC/SDXC card |
| USB | USB 2.0 (480 Mbit/sec) |
| Weight (inc. batteries) | 343 g (0.76 lb / 12.10 oz) |
| Dimensions | 112 x 68 x 45 mm (4.41 x 2.68 x 1.77) |
| GPS | None |






# LG WATCH STYLE កាន់តែស្តើង កាន់តែទំនើបជាងមុនទៅទៀត

នាឡិកាស្មាតវ៉ច LG Watch Style គឺជានាឡិកា Android ដែលមានរាងស្តើងជាងគេបំផុតក្នុងចំណោមស្មាតវ៉ចស្តើងៗដទៃទៀតដែរ។ ដំបូងគឺអ្នកប្រាកដជាគិតថាវាមានអេក្រង់ធំពេកពិបាកពាក់ខ្លាំងណាស់ តែផ្ទុយទៅវិញគឺបន្ទាប់ពីអ្នកបានពាក់វាប្រើប្រាស់កាន់តែយូរនោះអ្នកនឹងមានអារម្មណ៍ថាកាន់តែពេញចិត្តវាខ្លាំងឡើងៗ។ ដោយសារតែវាមានមុខងារ និងប្រព័ន្ធប្រើប្រាស់សម្រាប់អ្នកលេងកីឡានោះ គឺវាដើរតួនាទីយ៉ាងសំខាន់ក្នុងការហ្វឹកហាត់រាងកាយអ្នក ក៏ដូចជាថែទាំសុខភាពអ្នកឱ្យបានកាន់តែប្រសើរឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ សម្រាប់ LG Watch Style ដ៏ស្រស់ស្អាតនេះដែរក៏មានមានប្រើប្រាស់នូវបន្ទះអេក្រង់ដ៏មានគុណភាពផងដែរប្រភេទ Gorilla Glass 3 ទំហំ 1.2 អ៊ីញ និងប្រើប្រាស់បច្ចេកវិទ្យាបង្ហាញ P-OLED ព្រមជាមួយនឹង Resolution កម្រិត 360 x 360 ភីចសែលថែមទៀតផង។ ហេតុនេះគឺវាពិតជាផ្តល់ភាពងាយស្រួលដល់អ្នកក្នុងការប្រើប្រាស់នៅពេលឆែកមើលព័ត៌មានផ្សេងៗ ឬគ្រប់គ្រងបញ្ហាវាប្រើប្រាស់ជាដើម។ កញ្ចក់អេក្រង់របស់វាគឺមិនរងការកោសឆ្កូតដោយងាយៗនោះទេ ពីព្រោះថាវាមានប្រើប្រាស់នូវបច្ចេកវិទ្យា IP67 នៅខាងក្នុងនោះដើម្បីជួយឱ្យស្មាតវ៉ចមួយនេះមានរូបរាងដ៏រឹងមាំ ហើយធន់ជាមួយទាំងទឹក និងធូលី រួមទាំងការប៉ះទង្គិចផ្សេងៗ ឬក៏ធ្លាក់ជាយថាហេតុផងដែរ។ LG Watch Style ដំណើរការដោយប្រព័ន្ធប្រតិបត្តិការ OS Android Wear 2.0 ហើយប្រើប្រាស់ Processor ល្បឿន 1.1 GHz ប្រភេទ Qualcomm® SnapdragonTM Wear 2100 បូករួមទាំងប្រព័ន្ធផ្ទុកថាមពលប្រើប្រាស់ទំហំ 240 mAh ថែមទៀតផងនៅខាងក្នុង។ ជ្រើសរើស LG Watch Style គឺជ្រើសរើសភាពល្អប្រសើរសម្រាប់ជីវិតអ្នក។

## លក្ខណៈទូទៅ

| | |
|---|---|
| Protection | IP67 water-resistance and dust |
| display | 1.2-inch 360 x 360 P-OLED |
| Quick release straps | Stainless Steel 316L, Stainless Steel & Gorilla Glass 3 |
| | Italian Genuine Leather |
| OS | Android Wear 2.0* |
| Chipset | 1.1 GHz Qualcomm® SnapdragonTM Wear 2100 |
| Battery Capacity | 240 mAh (Embedded)** |
| Bluetooth® | Bluetooth Version 4.2 LE |
| Wi-Fi® Connectivity | 802.11 b/g/n RAM 512 MB |
| Storage Space | 4 GB |




# តាមដានសុខភាពរបស់អ្នកជាមួយ GARMIN VIVOSMART 3

## លក្ខណៈទូទៅ

| | |
|---|---|
| Product Type | activity tracker |
| Wearing Style | wrist |
| Clock Display | Yes |
| Integrated Com. | heart rate sensor |
| Sensors | accelerometer, altimeter, heart rate |
| Vibrating Alert | Yes |
| Color | black |
| Water Resistance | 164 ft Depth |
| Protection | 5ATM waterproof |
| Preloaded Software | VO2 Max, Fitness Age, Move IQ |
| Wireless Interface | Bluetooth, ANT/ANT+ |

នាឡិកាដៃតាមដានសុខភាព Garmin គឺកំពុងតែទទួលបានការគាំទ្រប្រើប្រាស់កាន់តែខ្លាំងឡើងៗ ហើយនៅក្នុងទីផ្សារបច្ចុប្បន្ននេះ ហើយនាពេលថ្មីៗនេះដែរគឺ Garmin ក៏បាននាំមកជូននូវ Fitness Tracker ស៊េរីថ្មីមួយទៀតហើយគឺ Garmin Vivosmart 3។ ប្រើប្រាស់ជាមួយនឹងស្មាត Tracker មួយនេះគឺអ្នកនឹងទទួលបានអត្ថប្រយោជន៍ជាច្រើន បូករួមជាមួយនឹងប្រព័ន្ធការពាររាងកាយដ៏មានសមត្ថភាព។ ចំពោះការរចនា Vivosmart 3 នាំមកជូនជាមួយនឹងរាងស្ដើង ហើយតូចមានប្រើប្រាស់ខ្សែស្រស់ស្អាតទៅតាមទំហំកដៃរបស់អ្នក និងមានច្រើនពណ៌សម្រាប់ធ្វើការជ្រើសរើសផងដែរ។ Garmin Vivosmart 3 ប្រើប្រាស់នូវអេក្រង់ OLED ដែលផ្ដល់ Resolution កម្រិត 64 x 128 ភីចសែល ហើយថែមទាំងប្រើប្រាស់ប្រព័ន្ធកំណត់ពន្លឺដោយស្វ័យប្រវត្តិទៀតផង ហេតុនេះគឺមិនថាអ្នកឆែកមើលវានៅក្រោមពន្លឺថ្ងៃចាំងយ៉ាងណា ក៏អ្នកអាចមើលវាបានច្បាស់ដែរ។ អ្នកអាចទំនាក់ទំនងជាមួយនឹងឧបករណ៍នេះដោយការប៉ះ ឬទាញអូសដោយផ្ទាល់នៅលើអេក្រង់រាងបញ្ឈររបស់វា ដើម្បីពិនិត្យមើលសកម្មភាពផ្សេងៗដែលអ្នកបានធ្វើ ឬពិនិត្យមើលសេចក្ដីណែនាំពីការថែទាំសុខភាពរបស់អ្នកផងនោះ។

ក្រៅពីនេះ Vivosmart 3 ក៏ជានាឡិកាដែលមិនជ្រាបទឹកនោះឡើយ ទោះបីអ្នកកំពុងហែលទឹក ឬមុជចូលទៅក្រោមផ្ទៃទឹកក៏ដោយ ក៏អ្នកមិនចាំបាច់ដោះវាចេញដែរ។ Vivosmart 3 អាចភ្ជាប់ប្រើប្រាស់បានជាមួយនឹងទូរស័ព្ទដែលដំណើរការដោយប្រព័ន្ធប្រតិបត្តិការទាំងAndroidនិងIOSអាស្រ័យលើកម្មវិធីជំនួយរបស់វារួមជាមួយនឹងប្រព័ន្ធ Bluetooth ផងដែរ៕




# Seagate Barracuda 4TB

## ផ្តល់សុវត្ថិភាពកាន់តែខ្ពស់ និងប្រសើរបំផុត

បន្ទាប់ពីទទួលបានជោគជ័យពីការបង្ហាញ Hard Disk សម្រាប់កុំព្យូទ័រកាលពីឆ្នាំមុនកន្លងទៅ ក្រុមហ៊ុនផលិត Hardware ដ៏ល្បី Seagate បានបន្តរក្សាភាពល្បីល្បាញរបស់ខ្លួនតទៅទៀតសម្រាប់ឆ្នាំថ្មីនេះ។ នាពេលថ្មីៗនេះ Seagate បានដាក់បង្ហាញបច្ចេកវិទ្យាចុងក្រោយរបស់ខ្លួនគឺ Barracuda ដែលវាបាននាំមកជូនជាមួយនឹងទំហំផ្ទុកទិន្នន័យ 4TB។ អ្វីដែលអ្នកគួរយល់ដឹងនោះគឺ ថាតើទំហំ 4TB របស់ Barracuda នេះមានភាពខុសគ្នាដូចម្តេច ហើយមានមុខងារល្អៗយ៉ាងដូចម្តេចខ្លះ បើប្រៀបធៀបជាមួយនឹង Hard Disk ម៉ាកដទៃទៀតនោះ។ សម្រាប់ Hard Disk ស៊េរីថ្មី Barracuda 4TB នេះគឺអាចដំណើរការបានលឿន (5900 rpm) សក្តិសមបំផុតសម្រាប់ដាក់នៅខាងក្នុងធ្វើជា Hard Disk ថ្មីដើម្បីផ្ទុកទិន្នន័យអ្នក ជាពិសេសនោះគឺវាមានតំលៃសមរម្យមិនធ្លាប់មានពីមុនមកនោះទេ។ ក្រៅពីមានល្បឿនដំណើរការល្អ និងមានតំលៃទាបហើយនោះ BarraCuda អាចបំពេញតម្រូវការខ្វះខាតគ្រប់យ៉ាងដែលកុំព្យូទ័រអ្នកត្រូវការ ក្នុងនោះរួមមានការដំឡើងកម្មវិធីផ្សេងៗប្រើប្រាស់ ឬកម្មវិធីកម្សាន្ត និងសម្រាប់ផ្ទុកភាពយន្ត តន្ត្រី ឬ Files ជាច្រើនផ្សេងទៀតដែលសំខាន់របស់អ្នកនោះ។ អស់រយៈពេលជាង 20 ឆ្នាំហើយដែលគ្រួសាររបស់ BarraCuda បាន




ជ្រើសរើសប្រើប្រាស់ Seagate Barracuda 4TB គឺជ្រើសរើសទំហំផ្ទុកទិន្នន័យដ៏មានសមត្ថភាពធ្វើឱ្យអ្នកប្រើប្រាស់ទទួលអារម្មណ៍ថាមានសុវត្ថិភាព និងពេញចិត្តប្រើប្រាស់ជាមួយនឹងបន្ទះ Hard Disk មួយនេះណាស់៕






ផ្តល់ជូនបន្ទះផ្ទុកទិន្នន័យដ៏មានទំនុកចិត្តខ្ពស់បំផុតក្នុងចំណោមក្រុមហ៊ុនផលិត Hard Disk ដទៃៗទៀត ដោយវាតែងតែប្រើប្រាស់នូវបច្ចេកវិទ្យាការពារទិន្នន័យអ្នកបានល្អបំផុត ជាក់ស្តែងនោះគឺវាមានប្រើប្រាស់បច្ចេកវិទ្យា Self-Encrypting Drive (SED) ដើម្បីជួយ Support លើបញ្ហានេះ។ ហើយប្រសិនបើអ្នកបានធ្វើឱ្យទិន្នន័យសំខាន់ណាមួយបានបាត់បង់ជាយថាហេតុនោះគឺអ្នកអាចទាញយកមកវិញបានយ៉ាងងាយស្រួលមែនទែន ហើយមិនប្រើពេលយូរនោះឡើយ។ បើធ្វើការប្រៀបធៀបជាមួយនឹងជំនាន់មុនរបស់វា យើងឃើញថា Hard Disk ជំនាន់ថ្មីនេះមានល្បឿនលឿនជាង បន្តែនៅតែមានសំឡេងរំខានដដែល ពីព្រោះថាបើ Hard Disk ណាដែលមិនមានសំឡេងខ្លាំងដំណើរការ នោះល្បឿនរបស់វាក៏មិនសូវជាលឿនប៉ុន្មានដែរ។

## ព័ត៌មានទូទៅ

| | |
|---|---|
| Brand | Seagate |
| Product name | BarraCuda New 4TB |
| Product code | ST4000DM005 |
| **Specifications** | |
| Disc type | Hard disk |
| Quoted capacity | 4000 GB |
| Rotation speed | 5900 rpm |
| Cache | 64 MB |
| Interface | Serial ATA 600 |
| Warranty | 2 year(s) |
| **Physical properties** | |
| Form factor | 3.5 inch |
| Height | 25.6 mm |
| Weight | 635 gram |




# Scythe Mugen 5 PCGH Edition

## ដំណើរការដោយភាពឆ្លាតវៃ

Scythe Mugen គឺជា Cooler មួយប្រភេទដែលមានជំនាញក្នុងការបន្ថយកំដៅពីបន្ទះ CPU នៃកុំព្យូទ័ររបស់អ្នកដើម្បីឱ្យកុំព្យូទ័រអ្នកអាចដំណើរការបានយ៉ាងស្រួល មិនបង្ករឱ្យអ្នកខានបង់ពេលវេលាការងារ ឬការកម្សាន្តរបស់អ្នកឡើយ។ នាពេលថ្មីៗកន្លងផុតទៅនេះ Scythe បានដាក់បង្ហាញសមាសធាតុបំភាយកំដៅជំនាន់ថ្មីគឺ Mugen 5 PCGH Edition ដែលមានន័យថាជា PC Game Hardware ជំនាន់ទី 5 របស់ Mugen (ក្រុមហ៊ុនផលិត Hardware ដ៏ល្បីឈ្មោះមួយក្នុងចំណោមក្រុមហ៊ុនល្បីៗនៅអាឡឺម៉ង់)។ ជាមួយនឹងសមាសធាតុដ៏មានសមត្ថភាពមួយនេះគឺអាចដំណើរការដោយខ្លួនឯង និងដោយស្វ័យប្រវត្តិ ហើយមិនបង្ករសំឡេងរំខានដល់អ្នកនៅពេលកំពុងប្រើប្រាស់កុំព្យូទ័ររបស់អ្នកនោះឡើយពោលគឺប្រសើរជាជំនាន់មុនរបស់វាតែម្តង។ បើពិនិត្យមកមើលការរចនារបស់វាយើងឃើញថា Mugen 5 PCGH បានប្រើប្រាស់គំនិតបង្កើតដ៏




សាមញ្ញបំផុត ដោយវាស្រូបកំដៅចេញពីបន្ទះ CPU នៃកុំព្យូទ័រអ្នកចូលទៅកាន់ផ្នែកខាងក្នុងនៃសមាសធាតុនេះ រួចហើយវាក៏ប្រើកង្ហារ Kaze Flex 120 (កង្ហារដែលដំណើរការយ៉ាងស្ងាត់ច្រងំ) ចំនួនពីរសម្រាប់បក់ខ្យល់ក្ដៅចេញមកខាងក្រៅ។ ក្រោយពី CPU ឡើងកំដៅភ្លាម គឺសមាសធាតុមួយនេះប្រើប្រាស់កង្ហាររបស់វាដើម្បីធ្វើឱ្យ CPU អ្នកចុះកំដៅបានរហ័ស ពីព្រោះកង្ហារទាំងពីររបស់វាអាចវិលបានចន្លោះពី 300 ទៅ 800 ជុំឯណោះក្នុងពេលមួយនាទី។ ដើម្បីឱ្យកាន់តែមានភាពប្រគួតប្រជែងបន្ថែមទៀតនោះ បន្ទះបំភាយកំដៅ Mugen បានបង្កើនសមត្ថភាពច្រើន ហើយ Support ប្រើប្រាស់ជាមួយនឹងរន្ធ AM4 ថែមទៀតផង មានន័យថាមិនថាអ្នកប្រើប្រាស់ CPU Intel ឬបន្ទះ CPU AMD Ryzen នោះទេគឺអាចប្រើប្រាស់បានជាមួយនឹងវាទាំងអស់។ Scythen Mugen 5 PCGH Edition ផ្ដល់ជូនគុណភាពប្រើប្រាស់លើសពីការរំពឹងទុករបស់អ្នកទៅទៀត ពោលគឺវាជួយអ្នកឱ្យអាចដំណើរការកុំព្យូទ័រអ្នកបានយ៉ាងស្រួល មិនថាអ្នកបើកកម្មវិធីធំៗក៏វាមិនចោទជាបញ្ហាអ្វីសោះឡើយចំពោះកុំព្យូទ័រអ្នក៕



### ព័ត៌មានទូទៅ

| | |
|---|---|
| Brand | Scythe |
| Product name | Mugen 5 PCGH Edition |
| Socket | 775 |
| Socket | 1150/1151/1155/1156 |
| Socket | 1366 |
| Socket | 2011 |
| Socket | AM2/AM3/AMD3+/FM1/FM2/FM2+ |
| Socket | AM1 |
| Socket | AM4 |
| Weight | 1034 gram |
| Height | 15.4 cm |
| Width | 12.8 cm |
| Depth | 13 cm |
| Fan used | 120 mm |
| Secondary fan included | 120 mm |
| Minimum RPM | 300 rpm |
| Maximum RPM | 800 rpm |
| Fan connector | 4 pins |
| Ball / Sleeve | Fluid Dynamic Bearing |
| Amount of heatpipes | 6 |
| Material | Copper / Aluminum |

# ឧបករណ៍អេឡិចត្រូនិចជំនួយ Accessories



## HP Elite 90W Thunderbolt 3 Dock ជួយបន្ថែមមុខងារបើបន្ថែមទៀតដល់កុំព្យូទ័រអ្នក

សូមទទួលយកនូវអារម្មណ៍រីករាយជាមួយនឹងការបង្ហាញខ្លួនរបស់ឧបករណ៍ជំនួយបន្ថែមរន្ធ USB ដល់កុំព្យូទ័រអ្នកដើម្បីផ្តល់ភាពងាយស្រួលក្នុងការប្រើប្រាស់ឱ្យបានកាន់តែសម្បូរបែបជាងមុន។ ជាមួយនឹងឧបករណ៍ Thunderbolt 3 Dock នេះគឺអ្នកអាចភ្ជាប់ប្រើប្រាស់អេក្រង់ UHD ឬ 4K មួយទៀតដើម្បីបន្ថែមភាពងាយស្រួលដល់អ្នកក្នុងការបើកកម្មវិធីច្រើនប្រើប្រាស់ ឬសម្រាប់ដោតភ្ជាប់ឧបករណ៍ជំនួយផ្សេងៗទៀតប្រើប្រាស់បានយ៉ាងមានរបៀបរាបរយនៅមួយកន្លែងតែម្តង។ ក្រៅពីនេះ អ្នកក៏អាចប្រើប្រាស់ Ports មួយចំនួនរបស់វាសម្រាប់ជាស្ពានក្នុងការបញ្ចូលថាមពលត្រលប់ទៅកាន់Laptopទូរស័ព្ទស្មាតហ្វូនឬថែបលែតក៏បានដែរ។ លើសពីនេះទៅទៀតនោះ ប្រសិនបើអ្នកចង់បញ្ជូនទិន្នន័យទៅកាន់ឧបករណ៍ USB ឬ External Hard Drive របស់អ្នកនោះ គឺឧបករណ៍ដ៏ស្រស់ស្អាតមួយនេះអាចប្រើប្រាស់បានជាមួយនឹងផត USB គ្រប់ប្រភេទទាំងអស់តែម្តង។ ជាការពិតណាស់គឺ Thunderbolt 3 Dock នេះដែរគឺបានផ្តល់ជូននូវផតចំនួន 10 ផត ហើយមិនទាមទារឱ្យអ្នកប្រើប្រាស់ខ្សែភ្ជាប់ច្រើនបង្ករភាពរញ៉េរញ៉ៃនៅពេលអ្នកប្រើប្រាស់កុំព្យូទ័ររបស់អ្នកនោះទេ ហើយអ្វីដែលសំខាន់នោះ គឺវាផ្តល់ល្បឿនលឿនថែមទៀតផង៕




# Lenovo 500 Bluetooth Speaker ប្រើប្រាស់មុខងារច្នៃប្រឌិតថ្មីដើម្បីទទួលបានប្រជាប្រិយភាពបន្ថែម

បង្កើនភាពសប្បាយរីករាយជាមួយនឹងឧបករណ៍រំពងសំឡេង Lenovo 500 នៅពេលជួបជុំបង្កើតកម្មវិធីកម្សាន្តមិនថានៅក្នុងផ្ទះ នៅឆ្នេរសមុទ្រ ឬនៅទីណាកន្លែងណានោះទេគឺអ្នកនៅតែអាចប្រើប្រាស់វាបានដោយសេរីជាមួយនឹងគុណភាពសំឡេងដ៏ល្អឥតខ្ចោះថែមទៀតផង។ Lenovo 500 គឺជា Bluetooth Speaker មួយប្រភេទដែលមានរូបរាងស្រស់ស្អាត ប្រើប្រាស់បន្ទះលោហៈធាតុជាសម្បកការពាររាងការរបស់វា បើមើលពីក្រៅទៅគឺពិតជាទំនើបមែនទែន។ ពិតណាស់គឺនៅលើរាងកាយរបស់វាមានប៊ូតុងបញ្ជាតែមួយប៉ុណ្ណោះ ដោយអ្នកអាចប្រើប្រាស់វាបានច្រើនមុខងារ ជាក់ស្តែងនោះគឺអ្នកអាចប្រើវាដើម្បីគ្រប់គ្រងកម្រិតនៃសំឡេង កំណត់ការ Play ឬ Pause ជាដើម។ ម្យ៉ាងទៀតអ្នកក៏អាចភ្ជាប់វាប្រើប្រាស់ជាមួយ Laptop ឬក៏ស្មាតហ្វូនក៏បានដែរឱ្យតែពួកវាមាន Built-in នូវប្រព័ន្ធ Bluetooth ឬ supports NFC គឺបានទៅហើយ។ ហើយនៅពេលដែលអ្នកបើកវាប្រើប្រាស់ Lenovo 500 អាចបញ្ចេញសំឡេងបានឮច្បាស់ចេញពីគ្រប់ទិស ពីព្រោះវាមានប្រើប្រាស់នូវប្រព័ន្ធកាត់បន្ថយសំឡេងរំខានយ៉ាងពិសេសតែម្តងនៅខាងក្នុង។ ទន្ទឹមនឹងនេះដែរ ដោយសារតែវាមានប្រើប្រាស់នូវប្រព័ន្ធថ្មកំលាំង 1800 mhA នោះគឺអាចឱ្យអ្នកបន្តទទួលបានភាពសប្បាយរីករាយបានរហូតដល់ 4 ម៉ោងឯណោះសម្រាប់ការដោតបញ្ចូលថាមពលមួយលើកនោះ៕




## Marshall Monitor
## ជំនួយការថ្មីសម្រាប់ជួយបង្កើនទំនាក់ទំនង

បច្ចុប្បន្ននេះស្មាតហ្វូនគឺអាចភ្ជាប់អ្នកទៅកាន់គ្រប់ទីកន្លែងទាំងអស់នៅជុំវិញពិភពលោក ដើម្បីបង្កើនទំនាក់ទំនងជាមួយមនុស្សជាទីស្រលាញ់របស់អ្នកនៅពេលដែលអ្នកប្រើប្រាស់សេវាអ៊ីនធឺណេតនោះ។ កាសជាឧបករណ៍ដែលមានសារៈសំខាន់សម្រាប់អ្នក ពីព្រោះថាអ្នកអាចនឹងពិបាកប្រសិនបើការធ្វើទំនាក់ទំនងរបស់អ្នកមិនមានប្រើប្រាស់សំឡេង ឬមានដែរតែអ្នកពិបាកក្នុងការស្តាប់។ ស្របពេលនេះដែរ Marshall Monitor គឺជាកាសមួយដ៏ទំនើបដែលមិនត្រឹមតែជួយអ្នកសម្រាប់តែទំនាក់ទំនងតែមួយមុខនោះទេ តែវាក៏ជួយផ្តល់ការកម្សាន្តជាមួយនឹងតន្ត្រី ដែលអ្នកត្រូវការ។ Marshall Monitor ពិតជាផ្តល់ផាសុកភាពនៅពេលពាក់វាប្រើប្រាស់ ហើយអាចផ្តល់សំឡេងបានល្អ ថែមទៀតផងពោលគឺវាផ្តល់សំឡេងធំល្អ ច្បាស់ មិនបង្ករឱ្យមានសំឡេងរំខានមកពីខាងក្រៅដោយងាយៗនោះឡើយ។ Marshall Monitor ប្រើប្រាស់ប្រព័ន្ធ Bluetooth ដើម្បីឱ្យអ្នកអាចភ្ជាប់ស្មាតហ្វូនរបស់អ្នកប្រើប្រាស់បាន មិនចាំបាច់មានប្រើប្រាស់ខ្សែនោះទេ ហើយវាក៏មិនទាញយកថាមពលពីស្មាតហ្វូនរបស់អ្នកដែរ ពីព្រោះវាមាន Built-in មកជាមួយស្រាប់នឹងប្រព័ន្ធថ្មនៅខាងក្នុង។ ម្យ៉ាងទៀតប្រសិនបើវាអស់ថាមពលអ្នកគ្រាន់តែដោតវាបញ្ចូលថាមពលត្រលប់វិញគឺបានទៅហើយ។

## UE Wonderboom សមត្ថភាពលើសតែម្តង

Wonderboom គឺជា Speaker មួយដែលមានរូបរាងសាមញ្ញស្រដៀងគ្នាទៅនឹង Speaker ធម្មតាមួយដែរ ប៉ុន្តែសមត្ថភាពរបស់វាលើសពីរូបរាងរបស់វាដែលអ្នកបានឃើញទៅទៀត។ រឿងដ៏ល្អដែល Wonderboom បានផ្តល់ជូនមួយទៀតនោះគឺគុណភាពសំឡេងនេះឯងដោយមិនថាអ្នកដាក់វានៅទីតាំងណានោះទេគឺវានឹងបញ្ចេញសំឡេងមកខាងក្រៅជុំវិញខ្លួនរបស់វាតែម្តង។ ចំណែកឯប្រព័ន្ធថ្មអាចបើកប្រើប្រាស់វាបានរហូតដល់ទៅ 10 ម៉ោង ហើយប្រសិនបើអ្នកចង់ដែកមើលថាតើវានៅសល់ថាមពលប៉ុន្មានភាគរយនោះគឺអ្នកគ្រាន់តែចុចប៊ូតុង Volume ទាំងពីរព្រមគ្នានោះវានឹងផ្តល់សំឡេងប្រាប់ដល់អ្នកភ្លាមៗតែម្តង។ Wonderboom ពិតជាបានផ្តល់ទំនុកចិត្តដល់អ្នកប្រើប្រាស់មែនទែន ជាក់ស្តែងនោះគឺវាមានប្រព័ន្ធការពាររាងកាយដ៏រឹងមាំបំផុត (ប្រសិនបើវាជ្រុះដោយចៃដន្យកំពស់ក្រោម 2 ម៉ែត្រគឺវាមិនធ្វើឱ្យមានផលប៉ះពាល់អ្វីសោះឡើយ) ហើយប្រសិនបើវាធ្លាក់ចូលទឹកវិញក៏គ្មានបញ្ហាដែរពីព្រោះវាមានប្រព័ន្ធការពារមិនឱ្យទឹកជ្រាបចូល និងមិនលិចចូលទៅក្រោមផ្ទៃទឹកនោះទេ។






## Sony Xperia Touch អាចបង្កើត Projector បានល្អជាង Projector ធម្មតាទៅទៀត

Sony Xperia Touch គឺជាឧបករណ៍មួយដ៏ឆ្លាតវៃសម្រាប់បង្ហាញផ្ទៃនៃអេក្រង់ទូរស័ព្ទ Android របស់អ្នកឱ្យបានធំជាងមុនទៅលើផ្ទៃរាបស្មើណាមួយ ហើយអាចឱ្យអ្នកប៉ះបញ្ជាទៅលើពន្លឺ Projector របស់វាដោយផ្ទាល់ផងដែរ។ ជាមួយនឹង Projector នេះដែរគឺអ្នកអាចធ្វើការបង្ហាញបាន 2 ប្រភេទដាច់ដោយឡែកពីគ្នាដែលក្នុងនោះគឺអ្នកអាចប្ដូរទំហំអេក្រង់ស្មាតហ្វូនអ្នកទៅជាអេក្រង់ទំហំ 23 អ៊ីញ និងអាចបង្ហាញផ្ទៃក្រង់ថ្មីមួយទៀតនៅលើជញ្ជាំងបានរហូតដល់ទៅ 80 អ៊ីញឯណោះ។ Xperia Touch មិនត្រឹមតែអាចប្រើប្រាស់ជាមួយនឹងស្មាតហ្វូនតែមួយមុខនោះទេ តែអ្នកក៏អាចប្រើវាសម្រាប់ Share អេក្រង់ចេញពីកុំព្យូទ័រក៏បានដែរដែលក្នុងនោះគឺអ្នកអាចភ្ជាប់ដោយប្រើខ្សែក៏បាន ឬភ្ជាប់តាមប្រព័ន្ធ Wireless ក៏បានផងដែរ។ ហើយកាន់តែទំនើបថែមទៀតនោះគឺឧបករណ៍ដ៏តូចមួយនេះបាន Built-in ជាមួយនឹងប្រព័ន្ធ Speaker ដែលអាចផ្ដល់សំឡេងបានច្បាស់ប្រកបទៅដោយគុណភាពខ្ពស់ ជាពិសេសនោះវាក៏បានភ្ជាប់មកជាមួយនឹង Laser សម្រាប់ Focus នៅពេលដែលអ្នកប្រើប្រាស់អេក្រង់នៅលើជញ្ជាំង (80 អ៊ីញ) ៕

## LG Tone Studio អាចប្រើជាកាស និង Speaker ហើយមុខងារក៏ឆ្លាតវៃទៀតផង

ទោះបីជា LG មិនសូវជាបានផលិតស្មាតហ្វូនញឹកញាប់នោះគឺមកពី LG បានចំណាយពេលជាច្រើនផ្ដោតសំខាន់ទៅលើការផលិតឧបករណ៍ Audio សម្រាប់ប្រើប្រាស់ទៅវិញ។ ហើយនាពេលថ្មីៗនេះដែរគឺក្រុមហ៊ុននេះបានដាក់បង្ហាញនូវផលិតផលចុងក្រោយរបស់ខ្លួន LG Tone Studio នៅលើទីផ្សារ ជាមួយនឹងចំណុចទាក់ទាញជាច្រើន និងមានប្រយោជន៍សម្រាប់អ្នក។ LG Tone Studio ផ្ដល់ជូននូវមុខងារប្រើប្រាស់ 2 ដាច់ដោយឡែកពីគ្នា សម្រាប់មុខងារទីមួយគឺ LG Tone Studio នេះដែរគឺវាបាននាំមកជូននូវ Stereo Speaker ដែលមានប្រើប្រាស់សំឡេងប្រភេទ Real 3D Surround Sound នៅជុំវិញ ក របស់អ្នក រីឯមុខងារមួយទៀតវិញក៏អាចផ្ដល់សំឡេងបានច្បាស់ដូចគ្នាដែរដោយនៅពេលដែលអ្នកចង់ស្ដាប់កាស អ្នកគ្រាន់តែហូតទាញវាចេញដាក់ភ្ជាប់នឹងត្រចៀកអ្នកទៅគឺបានទៅហើយ។ ហើយប្រសិនបើអ្នកឈប់ស្ដាប់អ្នកអាចដាក់វាចូលទៅវិញបាន។ Tone Studio មានប្រើប្រាស់មុខងារពិសេសៗជាច្រើនទៀត ក្នុងនោះគឺវាមានមុខងារ Play/Pause តន្ត្រី មានប៊ូតុងសម្រាប់ទទួលការហៅចូល ឬបញ្ចប់ការសន្ទនាជាដើម។ ចំណែកឯប្រព័ន្ធថ្មរបស់វាគឺបានផ្ដល់លទ្ធភាពប្រើប្រាស់ល្អគួរសម បើអ្នកប្រើប្រាស់វាជា Speaker នោះអ្នកនឹងអាចប្រើប្រាស់វាបានពី 5 ទៅ 6 ម៉ោង ប៉ុន្តែប្រសិនបើអ្នកគ្រាន់តែប្រើប្រាស់វាជាកាសធម្មតាគឺអ្នកអាចបន្តប្រើប្រាស់វាបានជាង 35 ម៉ោងឯណោះសម្រាប់ការបញ្ចូលថាមពលមួយលើក៕



# ម៉ូដែលទូរស័ព្ទថ្មីៗ

# Phone Release

## Samsung Galaxy Note 8

Galaxy Note 8 គឺជាស្មាតហ្វូន Android ម៉ូដែលថ្មី និងជាស្មាតហ្វូនដែលប្រើប្រាស់ប្រព័ន្ធ Hardware ទំនើបៗចុងក្រោយផងដែរ។ ស្មាតហ្វូនមួយនេះដែរគឺត្រូវបានបំពាក់ឱ្យប្រើប្រាស់ផងដែរនូវអេក្រង់ដែលមានទំហំធំ 6.3 អ៊ីញលាតសន្ធឹងរហូតដល់គែមសងខាងតែម្តង ហើយដើម្បីឱ្យផ្ទាំងដែលបង្ហាញឡើងកាន់តែស្រស់ស្អាតនោះគឺ Samsung បានប្រើប្រាស់អេក្រង់ប្រភេទ AMOLED ហើយផ្តល់ Resolution ខ្ពស់ថែមទៀតផងនោះ។ ចំណែងប្រព័ន្ធកាមេរ៉ារបស់វាវិញគឺពិតជាទំនើបខ្លាំងណាស់ ដោយនៅផ្នែកខាងក្រោយគឺបានបំពាក់ទៅដោយប្រព័ន្ធកាមេរ៉ាភ្លោះទំហំ 13 មេហ្គា-ភីចសែល និងប្រើប្រាស់ 8 មេហ្គាភីចសែលសម្រាប់ថតរូបនៅផ្នែកខាងមុខ។ ហើយដើម្បីផ្តល់ភាពងាយស្រួលក្នុងការប្រើប្រាស់នោះ Samsung បានដាក់ប្រព័ន្ធដំណើរការ Android 7.0 ព្រមជាមួយនឹង Memory ទំហំ 64GB ផងដែរនៅខាងក្នុង៕






## Google Pixel 2

ស្មាតហ្វូនស៊េរីថ្មី Google Pixel 2 របស់ Google ត្រៀមនឹងបង្ហាញខ្លួនក្នុងពេលឆាប់ៗខាងមុខនេះហើយ ដោយស្មាតហ្វូនមួយនេះបានផ្ដល់ជូនជាមួយនឹងរូបរាងដ៏គួរឱ្យទាក់ទាញ រួមជាមួយនឹងប្រព័ន្ធ Hardware និង Software ទំនើបៗកំពុងពេញនិយមបំផុតនៅលើទីផ្សារបច្ចុប្បន្ន។ ជាក់ស្ដែងនោះគឺវានឹងប្រើប្រាស់ប្រព័ន្ធដំណើរការ Android O ហើយបង្កើនសមត្ថភាពទៅលើប្រព័ន្ធកាមេរ៉ាថតរូប ទៅលើបន្ទះ Processor និងទៅលើកូនកម្មវិធី Google Assistant មួយចំនួនទៀតផងដែរ។ ក្នុងនោះគឺ Google Pixel 2 ប្រើប្រាស់បន្ទះ Processor ម៉ូដែល Snapdragon 835 ដំណើរការរួមគ្នាជាមួយនឹងប្រព័ន្ធ RAM ទំហំ 4GB និង Memory ទំហំ 64GB ទៀតផងនៅខាងក្នុង។ ក្រៅពីនេះ Pixel 2 ក៏បានប្រើប្រាស់នូវអេក្រង់ទំហំ6អ៊ីញធ្វើការបង្ហាញឡើងជាមួយនឹង Resolution 2560 x1440 ភីចសែលព្រមទាំងមានប្រើប្រាស់នូវប្រព័ន្ធកាមេរ៉ាដ៏ទំនើបទំហំ 12 និង 8 មេហ្គាភីចសែលសម្រាប់ផ្នែកខាងក្រោយ និងផ្នែកខាងមុខរៀងគ្នាតែម្ដង៕




## Moto X4

ស្មាតហ្វូនជំនាន់ថ្មីរបស់ Motorola នឹងបង្ហាញខ្លួនជាមួយនឹងប្រព័ន្ធរុករកថ្មី មិនប្រើបណ្តុំកម្មវិធីរបស់ Google នោះទេ ដោយក្រុមហ៊ុនបានរំពឹងទុកថាស្មាតហ្វូន Moto X4 នឹងមានអ្នកគាំទ្រប្រើប្រាស់ច្រើនជាក់ជាមិនខានឡើយ។ ស្មាតហ្វូននេះបាននាំមកជាមួយនឹង Processor ស៊េរីថ្មី Snapdragon 630 ដំណើរការរួមគ្នាជាមួយនឹង RAM ទំហំ 4 ឬ 6GB និងទំហំផ្ទុកទិន្នន័យអចិន្ត្រៃយ៍ 64GB ថែមទៀតផង។ ជាមួយគ្នានេះដែរគឺ Moto X4 ក៏បានប្រើប្រាស់នូវប្រព័ន្ធផ្គត់ផ្គង់ថាមពលនៅខាងក្នុងទំហំ 3,000 mAh ហើយមានប្រើប្រាស់នូវប្រព័ន្ធកាមេរ៉ាភ្លោះថែមទៀតផងសម្រាប់ថតរូបនៅផ្នែកខាងក្រោយ។ អ្វីដែលជួយធ្វើឱ្យស្មាតហ្វូនមួយនេះមានភាពទាក់ទាញបន្ថែមមួយកម្រិតទៀតនោះគឺថាដោយសារតែវាមានរូបរាង រឹងមាំ ស្រស់ស្អាតដូចកញ្ចក់ ហើយថែមទាំងមានប្រព័ន្ធការពារការជ្រាបទឹក និងធូលីពីខាងក្រៅផងនោះ៕

# XIAOMI REDMI 5

ស្មាតហ្វូន Redmi 5 របស់ Xiaomi គឺជាស្មាតហ្វូនដំទំនើបមួយដែលក្រុមបានផ្ដល់ជូនជាមួយនឹងរាងកាយលោហៈធាតុ និងមានប្រើប្រាស់ប្រព័ន្ធស្កែនម្រាមដៃនៅផ្នែកខាងក្រោយផងដែរ។ Redmi 5 ផ្ដល់ឱ្យប្រើប្រាស់ជាមួយបន្ទះអេក្រង់ទំហំ 5 អ៊ីញដែលធ្វើការបង្ហាញតាមបែប full-HD (1080p) IPS ហើយមានប្រើប្រាស់ប្រព័ន្ធកាមេរ៉ាទំហំ 16 មេហ្គាភីចសែលនៅផ្នែកខាងក្រោយ និងប្រើប្រាស់ទំហំ 5 មេហ្គាភីចសែលសម្រាប់ផ្នែកខាងមុខ។ នៅផ្នែកខាងក្នុងនៃទូរស័ព្ទនេះដែរគឺត្រូវបានបំពាក់ឱ្យប្រើប្រាស់នូវ Processor ម៉ូដែល Snapdragon 630 ដែលផ្ដល់ល្បឿនដំណើរការ 2.2GHz ព្រមទាំងមានដំណើរការដោយ RAM ទំហំ 3GB និងប្រព័ន្ធ Memory ទំហំ 32GB ថែមទៀតផង។ ទន្ទឹមនឹងនេះដែរគឺ Redmi 5 បានដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធប្រតិបត្តិការ Android 7.1.1 Nougat ដំណើរការរួមគ្នាជាមួយនឹងប្រព័ន្ធ MIUI 9 របស់ក្រុមហ៊ុនផ្ទាល់តែម្ដង៕



# កម្មវិធីល្អបំផុតសម្រាប់ប្រព័ន្ធប្រតិបត្តិការ iOS

សម្រាប់ខែសីហានេះវិញ កម្មវិធីថ្មីៗដ៏អស្ចារ្យជាច្រើនត្រូវបានបង្ហោះចូលទៅក្នុងហាងទំនិញរបស់ App Store ជារៀងរាល់ថ្ងៃ។ ប៉ុន្តែលោកអ្នកប្រហែលជាមិនទាន់បានប្រើប្រាស់នូវកម្មវិធីថ្មីៗទាំង 5 នេះទេដែលយើងបានរកឃើញថាវាពិតជាអស្ចារ្យ និងមានសារៈប្រយោជន៍ច្រើនពិសេសជាងកម្មវិធីផ្សេងទៀត។ ពេលនេះ យើងនឹងធ្វើការបង្ហាញនូវកម្មវិធីថ្មីៗដែលអស្ចារ្យបំផុតសម្រាប់ឧបករណ៍ចល័តរបស់ក្រុមហ៊ុន Apple។




## Enlight Photofox (Enlight 2) អ្នកជំនាញកែប្រែរូបភាពដ៏អស្ចារ្យ

លោកអ្នកនឹងមិននឹកស្មានដល់នោះទេដែលលោកអ្នកអាចបង្កើតនូវរូបភាពកាន់តែអស្ចារ្យជាច្រើននៅលើទូរស័ព្ទ iPhone តាមរយៈកម្មវិធី Enlight Photofox ។ កម្មវិធីនេះមានលក្ខណៈពិសេសក្នុងការកែប្រែរូបភាពកាន់តែសម្បូរបែបដោយសារតែវាមានភ្ជាប់ជាមួយនឹង Layers ជាច្រើន និង Blending ModesរួមទាំងEffectsពិសេសៗជាច្រើនទៀត។កម្មវិធីនេះភ្ជាប់ជាមួយនឹង Photofox Photo Editor លោកអ្នកអាចប្រើប្រាស់នូវ Brushes, Fonts, Tonal Adjustment, Film, Black & White និង Duo Presets ផងដែរ។ កម្មវិធីនេះមានលក្ខណៈពិសេសក្នុងការប្រើប្រាស់នូវ Layers ជាច្រើនដែលលោកអ្នកអាចកែប្រែនៅលើស្រទាប់នេះបានសម្រាប់បង្កើតរូបភាពស្រស់ស្អាតគ្មានគូប្រៀបនោះទេនៅលើទូរស័ព្ទរបស់អ្នក៕




អ្នកអភិវឌ្ឍកម្មវិធី៖ Lightricks Ltd.
ទំហំ៖ ~ 142 MB

## Sticky AI អ្នកជំនាញបង្កើតរូបភាព Stickers ដ៏សម្បូរបែប!




តើលោកអ្នកចង់ចាប់ផ្ដើមការសន្ទនានៅលើ Chats របស់អ្នកនៅក្នុងកម្មវិធី Messenger ជាមួយនឹងកម្មវិធីថ្មីផ្ទាល់ខ្លួនដែរឬទេ? ឥឡូវនេះ លោកអ្នកអាចបង្កើតនូវ Stickers បានដោយខ្លួនឯងជាមួយនឹងកម្មវិធី Sticky AI ដែលជួយលោកអ្នកសម្រេចនូវក្ដីបំណងបានយ៉ាងងាយស្រួល និងលឿនបំផុតមិនគួរអោយជឿនោះទេ។ កម្មវិធីនេះប្រើប្រាស់គឺពិតជារហ័ស ហើយអ្នកអាចផ្ញើទៅកាន់កម្មវិធីផ្ញើសារបានជាច្រើនថែមទៀត។ រូបភាពដែលថតតាមរយៈកាមេរ៉ាមុខ Selfies នេះពិតជាអស្ចារ្យដោយសារតែលោកអ្នកអាចថតរូបជាស្ទាយថ្មីៗ និងបែបកំប្លែងៗបានយ៉ាងអស្ចារ្យមិនគួរអោយជឿនោះទេ។ កម្មវិធីនេះមានពន្លឺភ្លឺច្បាស់ និងពណ៌ផ្ទៃខាងក្រោយ Background ស្រស់ស្អាតមិនគួរអោយជឿនោះទេ។ កម្មវិធីនេះងាយស្រួលប្រើប្រាស់ ហើយវាមាន Interface ដ៏ទាក់ទាញថែមទៀត៕

អ្នកអភិវឌ្ឍកម្មវិធី៖ Prisma Labs, Inc.
ទំហំ៖ ~ 55 MB

## Text Art អ្នកជំនាញបន្ថែមស្ទាយដ៏សម្បូរបែបនៅលើរូបភាព!




នៅក្នុងពេលខ្លះ លោកអ្នកប្រហែលជាចង់បញ្ចេញនូវអារម្មណ៍របស់អ្នកនៅលើរូបភាពមុនពេលបង្ហោះនៅលើបណ្ដាញសង្គម Social Media ដែលមានការដាក់អក្សរយ៉ាងស្រស់ស្អាតដើម្បីស៊ីទៅនឹងអត្ថន័យនៃរូបភាពរបស់អ្នក។ អ្វីដែលកាន់តែពិសេសជាងនេះទៀតនោះ លោកអ្នកប្រហែលជាចង់ភ្ជាប់នូវកាតពិសេសមួយទៅកាន់ក្រុមគ្រួសារ និងមិត្តភក្តិរបស់អ្នកបានយ៉ាងសម្បូរបែប។ កម្មវិធីថ្មី Text Art ជួយលោកអ្នកក្នុងការបង្កើតរូបភាពកាន់តែអស្ចារ្យនៅក្នុងការបន្ថែមនូវតួអក្សរដ៏សម្បូរបែបដែលពិតជាមានភាពងាយស្រួល និងស្រស់ស្អាតដ៏សម្បូរបែប។ កម្មវិធី Text Art ប្រើប្រាស់នូវ Background Wallpapers និង Fonts ដ៏ទំនើបអស្ចារ្យសម្រាប់ប្រើប្រាស់នៅលើ Social Media, Blog/Website, Banner / Logos/ Watermarks, Books/ Album Cover និងការរចនានៅលើអាវយឺតថែមទៀត។ កម្មវិធី Art Text នេះអាចប្រើប្រាស់សម្រាប់ការរចនានៅលើកាតជាច្រើនផ្សេងៗគ្នាសម្រាប់ផ្ញើទៅកាន់ដៃគូជាច្រើនដ៏អស្ចារ្យតាមតែអ្នកត្រូវការ៕

អ្នកអភិវឌ្ឍកម្មវិធី៖ SafeSpace, Inc.
ទំហំ៖ ~ 72 MB

## Seeing AI អ្នកជំនាញក្នុងការសន្ទនានៃបច្ចេកវិទ្យាទំនើប!

Seeing AI គឺជាកម្មវិធីដ៏ពិសេសដែលមានសមត្ថភាពក្នុងការភ្ជាប់ទំនាក់ទំនងយ៉ាងជិតស្និទ្ធិនូវអ្វីៗដែលស្ថិតនៅជុំវិញអ្នកបានកាន់តែអស្ចារ្យ។ កម្មវិធីនេះត្រូវបង្កើតឡើងយ៉ាងពិសេសសម្រាប់អ្នកដែលខ្សោយភ្នែក ឬមនុស្សងងឹតមើលភ្នែកមិនឃើញសម្រាប់ការប្រើប្រាស់បច្ចេកវិទ្យា AI ដើម្បីជួយពួកគេអោយទំនាក់ទំនងទៅកាន់មនុស្សជុំវិញខ្លួនបានកាន់តែសម្បូរបែប ហើយជាពិសេសពួកគេក៏អាចទំនាក់ទំនងជាមួយនឹងវត្ថុដែលនៅជុំវិញខ្លួនរបស់ពួកគេបានផងដែរ។ កម្មវិធីនេះប្រើប្រាស់ជាមួយនឹង VoiceOver ដែលអនុញ្ញាតអោយលោកអ្នកអាចសម្គាល់នូវតួអក្សរ ឯកសារ ផលិតផល មនុស្ស ទិដ្ឋភាព និងរូបភាពជាច្រើនទៀតបានយ៉ាងងាយស្រួល។ កម្មវិធីនេះអាចប្រើប្រាស់សម្រាប់ចែករំលែកនៅក្នុង Mail, Photos, Twitter និងជាច្រើនទៀត។ សូមលោកអ្នកចងចាំផងដែរថា កម្មវិធី Seeing AI ត្រូវបានជួយលោកអ្នកអោយមានជីវិតកាន់តែប្រសើរឡើងតាមរយៈការប្រើប្រាស់បច្ចេកវិទ្យា AI នេះ៕

អ្នកអភិវឌ្ឍកម្មវិធី៖ Microsoft Corporation
ទំហំ៖ ~ 224 MB




## Blink អ្នកជំនាញក្នុងការកាត់តវីដេអូដ៏សម្បូរបែប!

Blink គឺជាកម្មវិធីកាត់តវីដេអូប្រភេទ Real Time Video Editor ដែលភ្ជាប់ជាមួយនឹងមុខងារកាន់តែសម្បូរបែបក្នុងការកម្សាន្តដូចជា Adjustments, Filters និង Tools ជាច្រើនទៀតសម្រាប់ការកាត់តវីដេអូដោយគ្មានការរង់ចាំ និងចំណាយពេលវេលា Renders នោះទេ។ កម្មវិធីនេះមានលក្ខណៈពិសេសក្នុងការកាត់តវីដេអូដោយសារតែវាប្រើប្រាស់នៅលើអេក្រង់ជាមួយនឹងកម្រិតល្បឿនដល់ទៅ 30,60,120 និង 240 fps និងការបើកមើលនៅក្នុង Full Screen ផងដែរ។ កម្មវិធីនេះក៏អាចធ្វើការ Import វីដេអូចេញពីស្មាតហ្វូនរបស់លោកអ្នកដូចជា Photos Library, iCloud Drive, iTunes, Dropbox, Box, Google Drive និង One Drive ។ កម្មវិធីនេះមានលក្ខណៈពិសេសក្នុងការកែប្រែទៅលើ Brightness, contrast, saturation, hue, vibrancy, highlights, shadows, exposure និង gamma ហើយវាក៏ភ្ជាប់ជាមួយ levels Tools សម្រាប់ធ្វើការ Render ផងដែរ៕

អ្នកអភិវឌ្ឍកម្មវិធី៖ Anomalous LLC
ទំហំ៖ ~ 22 MB



# កម្មវិធីថ្មីៗ




## Total Webmail Converter អ្នកជំនាញគ្រប់គ្រង និងបម្លែងទៅលើ Webmail!

Total Webmail Converter គឺជាកម្មវិធីមួយដែលមានទំហំតូចប៉ុន្តែវាមានសមត្ថភាពខ្លាំងក្នុងការបម្លែងនូវ Email របស់លោកអ្នក និងរក្សាទុកត្រឡប់មកវិញជាប្រភេទ Formats ថ្មីយ៉ាងសម្បូរបែប។ កម្មវិធីនេះអាចប្រើប្រាស់បានជាមួយនឹង Gmail, Yahoo និង Lotus ។ កម្មវិធី Total Webmail Converter អាចទាញយកនូវអ៊ីម៉ែលចេញពីគណនី POP3 ដោយផ្ទាល់បានហើយវាអាចបម្លែងទៅជាប្រភេទ .PDF, .HTML, .DOC, .TXT, .TIFF, .JPEG និង .RTF ។ តើកម្មវិធីនេះមានលក្ខណៈពិសេសអ្វីខ្លះទៅ? កម្មវិធីនេះអាចប្រើប្រាស់បានជាមួយនឹងសេវាកម្ម Emails ជាច្រើនហើយវារក្សាទុកទិន្នន័យបានច្រើនប្រភេទ ពិសេសវាមានកំណត់នូវកាលបរិច្ឆេទដើម្បីអោយលោកអ្នកងាយស្រួលគ្រប់គ្រង។ កម្មវិធីនេះឆ្លើយតបរហ័សហើយវាមានមុខងារជាច្រើនដែលជាតម្រូវការរបស់អ្នក៕



| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 27 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## Total Thunderbird Converter អ្នកជំនាញបម្លែងទិន្នន័យដ៏អស្ចារ្យ!

Total Thunderbird Converter គឺជាកម្មវិធី Tools មួយដ៏មានប្រយោជន៍បំផុតក្នុងការប្រើប្រាស់នៅលើ Mozilla Thunderbird .MBOX និង Email-Data ដែលរក្សាទុកនៅខាងក្នុង។ កម្មវិធីនេះអាចធ្វើការបម្លែងទៅជាទិន្នន័យជាច្រើនដូចជា .DOC, .PDF, .HTML, .TXT, ឬ .TIFF ។ កម្មវិធី Total Thunderbird Converter ក៏មានសមត្ថភាពក្នុងការបម្លែងនូវ Emails បានច្រើនយ៉ាង។ អ្វីដែលកាន់តែពិសេសនោះ វាមាន Interface ស្រស់ស្អាតងាយស្រួលប្រើប្រាស់ និងបង្ហាញនូវព័ត៌មានលម្អិតជាច្រើនទៀតដ៏អស្ចារ្យ។ កម្មវិធីនេះអាចធ្វើការភ្ជាប់ទំនាក់ទំនងទៅកាន់ Thunderbird Client នៅក្នុងវិធីដ៏សាមញ្ញ ហើយវាមានទម្ងន់ស្រាលក្នុងការប្រើប្រាស់មិនធ្វើអោយយឺតម៉ាស៊ីននោះទេ។ កម្មវិធីនេះថែមទាំងផ្តល់នូវវិធីសាស្ត្រជាច្រើនក្នុងការដំណើរការនូវ Email Attachment សម្រាប់ការគ្រប់គ្រងឯកសារនៅក្នុង Folder ដូចគ្នា៕



| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 12 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## Total CAD Converter អ្នកជំនាញបម្លែងទិន្នន័យ CAD ផ្តល់ជម្រើសច្រើន

Total CAD Converter គឺជាកម្មវិធីថ្មីមួយដែលមានសមត្ថភាពក្នុងការបម្លែងទិន្នន័យរបស់ CAD ទៅក្នុងទម្រង់ PDF, TIFF, JPEG, BMP, WMF, PNG, DXF, BMP, CGM, HPGL, SVG, PS និង SWF file formats ។ កម្មវិធីនេះថែមទាំងអាចទ្រទ្រង់នូវ Formats ជាច្រើនទៀតបានដូចជា DXF, DWG, DWF, DWFX, PLT, HG, HGL, HPG, PLO, HP, HPL, HPLG, HP1, HP2, HPGL2, GL2, SPL, SVG និង CGM ។ តើកម្មវិធីនេះភ្ជាប់ជាមួយនឹងលក្ខណៈសម្បត្តិអ្វីខ្លះទៅ? ជាក់ស្តែង កម្មវិធី Total CAD Converter ផ្តល់នូវលក្ខណៈពិសេសកាន់តែសម្បូរបែបក្នុងការ Rotate, Resize, Crop, Watermarks និងជាច្រើនទៀត។ លោកអ្នកអាចបម្លែងនូវរូបភាពជាច្រើនទៅជាទម្រង់ពណ៌សខ្មៅសម្រាប់ CAD Drawing។ កម្មវិធីនេះមានភាពងាយស្រួលក្នុងការប្រើប្រាស់ដោយសារតែ Interface របស់វា និងលក្ខណៈសម្បត្តិអស្ចារ្យជាច្រើនទៀត៕



| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 29 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## Total CSV Converter អ្នកជំនាញក្នុងការបម្លែងទិន្នន័យប្រភេទ CSV និង TSV

Total CSV Converter គឺជាកម្មវិធីដែលមានទម្ងន់ស្រាលក្នុងការប្រើប្រាស់សម្រាប់ធ្វើការបម្លែងទិន្នន័យជាប្រភេទ CSV និង TSV ទៅជាប្រភេទទិន្នន័យ .DOC, .PDF, .HTML, .TXT, .XLS, .XLSX, .DBF, .XML, .JSON និង OpenOffice ជាច្រើនទៀត។ កម្មវិធីនេះមិនមែនប្រើប្រាស់ជា Standard File Tools តែមួយមុខនោះទេ ប៉ុន្តែកម្មវិធីមួយនេះអនុញ្ញាតអោយលោកអ្នករៀបចំនូវ Options ជាច្រើន ហើយវាអាចផ្លាស់ប្តូរនូវ Parameters នៅក្នុងទម្រង់ជាច្រើនទៀតផង។ Interface របស់កម្មវិធីនេះពិតជាងាយស្រួលប្រើប្រាស់ ហើយវាភ្ជាប់ជាមួយនឹង menu Bar និងប៊ូតុងជាច្រើនទៀតដ៏អស្ចារ្យ។ សរុបមកកម្មវិធី Total CSV Converter ពិតជាអស្ចារ្យបំផុតក្នុងការប្រើប្រាស់ ហើយវាក៏ប្រើប្រាស់ជាមួយនឹង Wizard ដែលជួយលោកអ្នកសម្រេចគោលដៅបានឆាប់រហ័ស និងប្រកបដោយសុវត្ថិភាពថែមទៀត៕




| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 15 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## Total Doc Converter អ្នកជំនាញបម្លែងឯកសារ !

Total Doc Converter គឺជាកម្មវិធីដ៏មានប្រយោជន៍ដែលជួយបម្លែងទិន្នន័យឯកសាររបស់លោកអ្នកទៅក្នុងទម្រង់មួយថ្មី។ កម្មវិធីប្រើប្រាស់នូវបច្ចេកវិទ្យាកម្រិតខ្ពស់ក្នុងការប្រើប្រាស់ Command Line ដើម្បីធ្វើរឿងអស្ចារ្យជាច្រើនដែលលោកអ្នកនឹកស្មានមិនដល់។ តើកម្មវិធី Total Doc Converter អាចធ្វើរឿងអ្វីខ្លះបានទៅ? ជាក់ស្តែង កម្មវិធីតូចមួយនេះមានសមត្ថភាពក្នុងការប្រែក្លាយទិន្នន័យប្រភេទ DOC របស់លោកអ្នកទៅជាប្រភេទជាច្រើនដែលអ្នកប្រថ្នាចង់បាន។ កម្មវិធីនេះមានប្រើប្រាស់នូវ Page Counter, Date, Watermark និងទ្រទ្រង់ការប្រើប្រាស់ QR Code ផងដែរ។ កម្មវិធីនេះអាចប្រើប្រាស់បាននៅលើកម្មវិធី Microsoft Word 2010 និង Word 2003 បានផងដែរ។ កម្មវិធី Total Doc Converter ពិតជា Tools មួយដែលមានលក្ខណៈងាយស្រួលក្នុងការប្រើប្រាស់ ៕



| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 19 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## Total Excel Converter អ្នកជំនាញបម្លែងទិន្នន័យប្រភេទ Excel ដ៏សម្បូរបែប !

ប្រសិនបើលោកអ្នកកំពុងតែប្រើប្រាស់កម្មវិធី Excel នោះ កម្មវិធី Total Excel Converter ពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការប្រើប្រាស់។ កម្មវិធីនេះភ្ជាប់ជាមួយនឹងលក្ខណៈពិសេសក្នុងការបម្លែងឯកសារយ៉ាងច្រើនសម្បូរបែបតាមតម្រូវការរបស់អ្នក។ កម្មវិធី Total Excel Converter អាចធ្វើការបម្លែងនៅលើ Sheet ទៅក្នុងទម្រង់ថ្មីមួយ ហើយវាអាចធ្វើការបម្លែងទិន្នន័យប្រភេទ OpenOffice ODS ទៅជាប្រភេទ Microsoft XLS បានផងដែរ។ កម្មវិធី Total Excel Converter មានភាពងាយស្រួលហើយវាអាចរក្សានូវទិន្នន័យដើមមិនអោយមានការខូចខាតអ្វីនោះទេ។ តើ Format អ្វីខ្លះដែលកម្មវិធី Total Excel Converter នេះទ្រទ្រង់នោះ? កម្មវិធីនេះទ្រទ្រង់នូវ Formats ជាច្រើនដូចជា DOC, PDF, HTML, MHT, XHTML, CSV, TXT, TIFF, JPEG, SVG, RTF, XML, XLS, XLSX, ODS, ODT និងជាច្រើនទៀត៕



| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 22 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## Total HTML Converter អ្នកជំនាញបម្លែងទិន្នន័យនៅលើ HTML!

Total HTML Converter គឺជាកម្មវិធីមួយដ៏មានប្រយោជន៍ដែលមានលក្ខណៈពិសេសក្នុងការប្រើប្រាស់ដោយសារតែកម្មវិធីនេះមានសមត្ថភាពក្នុងការបម្លែងទិន្នន័យពីប្រភេទ HTML Files ទៅជាប្រភេទ DOC, PDF, HTML, XHTML, TXT, XLS, RTF, TIFF, JPEG, PNG, ODT, EMF ឬ SVG file formats ជាដើម។ កម្មវិធីនេះមាន Interface ងាយស្រួលប្រើប្រាស់ និងទាក់ទាញហើយវាអាចបញ្ជាតាម Command Prompt បានថែមទៀត។ កម្មវិធីនេះអាចបន្ថែមនូវទិន្នន័យជាច្រើនទៀតទៀតដូចជាកាលបរិច្ឆេទ និងពេលវេលាទៅក្នុងទំព័រនីមួយៗបានផងដែរ ហើយជាពិសេសលោកអ្នកអាចបន្ថែមនូវ Watermark ទៅលើ Files ណាមួយដែលអ្នកពេញចិត្តថែមទៀត។ កម្មវិធីនេះទ្រទ្រង់នូវការប្រើប្រាស់នូវ IE Footer & Header ហើយវាអាចបន្ថែមនូវហត្ថលេខាឌីជីថលថែមទៀតផង៕



| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
|---|---|---|---|
| 23 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## Total Image Converter អ្នកជំនាញបម្លែងរូបភាពដ៏ស្ទាត់ជំនាញ !

Total Image Converter គឺជាកម្មវិធីដ៏មានប្រយោជន៍ខ្លាំងក្នុងការប្រើប្រាស់នូវការបម្លែងនូវរូបភាពរបស់អ្នកទៅជាទម្រង់ Formats ជាច្រើនប្រភេទ ហើយលោកអ្នកអាចធ្វើការ Crop, Resize និង Rotate បានថែមទៀត។ កម្មវិធី Total Image Converter នេះក៏អនុញ្ញាតអោយលោកអ្នកបម្លែងនូវទិន្នន័យប្រភេទ TIFFs ទៅជាប្រភេទ JPEGs សម្រាប់ប្រើប្រាស់នៅលើគេហទំព័របានផងដែរ។ តើកម្មវិធី Total Image Converter មានលក្ខណៈពិសេសអ្វីខ្លះទៅ? កម្មវិធីនេះទ្រទ្រង់នូវ TIFF, JPEG, RAW, PNG, BMP, PSD, TGA និងជាច្រើនទៀតជាមួយនឹងបច្ចេកវិទ្យា Multi-Threading Technology រួមទាំងការបន្ថែមនូវ Watermark ជាច្រើនទៀត។ សរុបមក កម្មវិធី Total Image Converter គឺពិតជាដៃគូដ៏អស្ចារ្យមិនអាចរំលងបាននោះទេ៕

| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
| --- | --- | --- | --- |
| 26 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## Total Movie Converter អ្នកជំនាញទៅលើខ្សែភាពយន្ត !

Total Movie Converter គឺជាកម្មវិធីដ៏មានអានុភាពមួយដែលអាចបម្លែងនូវវីដេអូដែលអ្នកពេញចិត្តទៅជាប្រភេទ AVI, MPG, WMV, MPEG, FLV ហើយអ្វីដែលកាន់តែពិសេសជាងនេះទៀតនោះ កម្មវិធី Total Movie Converter អាចទ្រទ្រង់នូវវីដេអូបម្លែងសម្រាប់ឧបករណ៍ Apple TV, Archos, Xbox និង Platforms ជាច្រើនទៀតដោយគ្មានបញ្ហាអ្វីនោះទេ។ កម្មវិធីនេះមានលក្ខណៈសម្បត្តិអស្ចារ្យជាច្រើនគឺការទ្រទ្រង់នូវ MTS/M2TS រួមជាមួយនឹង Formats ជាច្រើនថែមទៀតដូចជា AVI, WMV, DIVX, VOB,MOV, MPEG, MPEG4, ASF, AVS, IVF,MKV, 3GP, HD, MOD, NSV, FLI, MTS និង Telesync ។ កម្មវិធីនេះក៏អាចធ្វើការបម្លែងទិន្នន័យចេញពីគេហទំព័រល្បីៗដូចជា YouTube និង Vimeo ផងដែរ។ កម្មវិធីនេះមានភាពងាយស្រួលប្រើប្រាស់ដោយសារតែវាមាន Interface ស្រស់ស្អាត និងការទ្រទ្រង់ Codec ឬ Format៕



| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
| --- | --- | --- | --- |
| 21 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |

## Total PDF Converter អ្នកជំនាញគ្រប់គ្រង និងបម្លែងទិន្នន័យ PDF!

Total PDF Converter គឺជាកម្មវិធីដ៏សម្បូរបែបសម្រាប់បម្លែងនូវទិន្នន័យជា PDF របស់អ្នកទៅជាប្រភេទ DOC, RTF, XLS, HTML, BMP, JPEG, GIF, WMF, EMF, PNG, EPS, PS, TIFF, TXT និង CSV។ អ្វីដែលកាន់តែពិសេសជាងនេះទៀតនោះ កម្មវិធី Total PDF Converter ភ្ជាប់ជាមួយនឹងសមត្ថភាពខ្លាំងក្លា និងពិសេសៗសម្រាប់ប្រើប្រាស់នៅលើកម្មវិធីដ៏អស្ចារ្យនេះ។ កម្មវិធី Total PDF Converter មានការរចនារូបរាងស្រស់ស្អាត និងងាយមើលសម្រាប់ការសិក្សាប្រើប្រាស់ចាប់តាំងពីកម្រិតដំបូងរហូតដល់អ្នកជំនាញ។កម្មវិធីនេះភ្ជាប់ជាមួយនឹងមុខងារជាច្រើនដ៏អស្ចារ្យ ហើយវាទ្រទ្រង់យ៉ាងតិចណាស់ 15 Formats ផ្សេងៗគ្នា។ ដូចនេះ លោកអ្នកមិនគួរមើលរំលងកម្មវិធី Total PDF Converter ដ៏អស្ចារ្យនេះណោះទេ។ ទាញយកឥឡូវនេះ ប្រើប្រាស់ឥឡូវនេះ និងចំណេញពេលវេលាបានច្រើនបំផុត៕



| ទំហំ | ប្រព័ន្ធដំណើរការ | ទីតាំងថតចម្លង | រយៈពេលប្រើប្រាស់ |
| --- | --- | --- | --- |
| 35 MB | គ្រប់ Windows | www.itcity.com.kh | បានរហូត |



# ហ្គេមអស្ចារ្យទាំង១០ ដែលពេញនិយមបំផុត លើប្រព័ន្ធប្រតិបត្តិការ iOS

ជារៀងរាល់សប្តាហ៍ហ្គេមថ្មីៗជាច្រើនបានបង្ហោះចូលទៅក្នុង App Store ឬ Play Store ប៉ុន្តែតើលោកអ្នកកំពុងតែស្វែងរកនូវហ្គេមដែលល្អលេងបំផុតនៅលើប្រព័ន្ធប្រតិបត្តិការ iOS និង Android មែនដែរឬទេ? ពេលនេះ លោកអ្នកមិនចាំបាច់ស្វែងរកនៅក្នុងហ្គេមរាប់រយរបស់ App Stores និង Play Store ទៀតនោះទេ ព្រោះយើងបានធ្វើការជ្រើសរើសនូវហ្គេមដែលអស្ចារ្យសប្បាយលេងជាទីបំផុត។ ខាងក្រោមនេះជាបញ្ជីហ្គេមដែលទទួលបានការគាំទ្រថាល្អបំផុតសម្រាប់លេងនៅលើប្រព័ន្ធប្រតិបត្តិការ iOS និង Android សម្រាប់ខែសីហា ឆ្នាំ 2017 នេះ។



## Missile Cards

**កាតព្វកិច្ចបាញ់មីស៊ីលកម្ចាត់សត្រូវ!**

Missile Cards គឺជាហ្គេមបាញ់ប្រហារដ៏សម្បូរបែបដែលផ្តល់នូវយុទ្ធសាស្ត្រកាន់តែអស្ចារ្យក្នុងការប្រកួតប្រជែង ហើយវាថែមទាំងផ្តល់នូវសង្គ្រាមប្រយុទ្ធគ្នាមួយដ៏សម្បូរបែប។ ហ្គេមដ៏អស្ចារ្យនេះត្រូវតម្រូវអោយលោកអ្នកប្រឹងប្រែងរៀបចំយុទ្ធសាស្ត្រថ្មីក្នុងការការពារនូវគ្រាប់មីស៊ីលនិងការធ្វើសង្គ្រាមនៅលើលំហរបាញ់អោយចំគោលដៅដើម្បីកម្ចាត់សត្រូវ។ ហ្គេមនេះមានលក្ខណៈពិសេសដោយសារវាមានការប្រកួតប្រជែងនៅក្នុងវគ្គធំៗចំនួន 5 ដែលអ្នកត្រូវឆ្លងកាត់ ហើយកម្រិតវគ្គនីមួយៗពិតជាមិនមែនងាយស្រួលក្នុងការយកឈ្នះនោះទេ។ លោកអ្នកត្រូវប្រើប្រាស់ជំនាញសមត្ថភាពរបស់អ្នកផ្ទាល់ដើម្បីកម្ចាត់សត្រូវជាច្រើនដែលរារាំងដំណើរផ្សងព្រេងរបស់អ្នក៕

អ្នកអភិវឌ្ឍហ្គេម៖ Nathan Meunier

ទំហំ៖ ~76 MB



## Prison Architect: Mobile

**ភារកិច្ចរំដោះឧក្រិដ្ឋជន!**

ការរត់គេចចេញពីពិភពលោកពិតជាងាយស្រួលមែន ប៉ុន្តែការរត់គេចចេញពីគុកមិនមែនជារឿងងាយស្រួលនោះទេ! ហ្គេម Prison Architect: Mobile ភ្ជាប់ជាមួយនឹងលក្ខណៈពិសេសក្នុងការរំដោះឧក្រិដ្ឋជនចេញពីគុក និងរត់គេចចេញពីការចាប់ខ្លួន។ នៅក្នុងហ្គេមដ៏អាថ៌កំបាំងនេះ គុកនេះមិនមែនមានការរចនាសាមញ្ញនោះទេ ប៉ុន្តែលោកអ្នកអាចនឹងវង្វេងផងដែរមុនពេលដែលអាចរត់គេចចេញពីគុកដ៏អស្ចារ្យមួយនេះ។ នៅក្នុងគុកនេះ វាមានកន្លែងវង្វេងៗជាច្រើនដែលអ្នកត្រូវឆ្លងកាត់ ហើយការធ្វើដំណើរកាន់តែវែងឆ្ងាយនឹងជួបនូវវគ្គលំបាកៗកាន់តែច្រើនឡើង។ ហ្គេមនេះមានលក្ខណៈពិសេសជាច្រើនទៀតដែលលោកអ្នកក៏នឹងត្រូវផ្តល់ភារកិច្ចដើម្បីធ្វើផងដែរ៕

អ្នកអភិវឌ្ឍហ្គេម៖ Paradox Interactive

ទំហំ៖ ~265 MB



## Hoggy 2

**ដំណើរផ្សងព្រេងដ៏គ្រោះថ្នាក់!**

Hoggy 2 គឺជាហ្គេមបែបផ្សងព្រេងដែលទទួលបានការពេញនិយម និងការកម្សាន្តជាច្រើន។ ហ្គេមនេះផ្ដល់នូវវគ្គថ្មីៗជាច្រើនសម្រាប់ការកម្សាន្ត ហើយវាមានវគ្គជាច្រើនរាប់រយដែលអ្នកនឹកស្មានមិនដល់នោះទេ។ ការធ្វើដំណើរកាន់តែឆ្ងាយ គ្រោះថ្នាក់ក៏កាន់តែច្រើនឡើងៗ។ វគ្គនីមួយៗលោកអ្នកត្រូវខិតខំប្រឹងប្រែងលេងដើម្បីធ្វើការដោះសោរនូវអាថ៌កំបាំងជាច្រើន។ លោកអ្នកអាចបង្កើតនូវកម្រិតវគ្គខ្លួនឯង រួមទាំងការប្រកួតប្រជែងជាច្រើនជាមួយអ្នកដ៏ទៃទៀតដើម្បីដោះសោរនូវមុខងារសំខាន់ៗជាច្រើនទៀត។ ហ្គេមនេះភ្ជាប់ជាមួយនឹង Editing Tools ជាច្រើន និងការប្រើប្រាស់ Quick Access សម្រាប់ដំណើរការបន្តនូវវគ្គថ្មីៗជាច្រើន។ តើលោកអ្នកសង្ឃឹមថានឹងអាចយកឈ្នះហ្គេមនេះបានដែរឬទេ? ហ្គេមនេះពិតជាសប្បាយលេង និងបង្កប់នូវវគ្គអាថ៌កំបាំងជាច្រើន។ តើលោកអ្នកអាចយកឈ្នះហ្គេមនេះបានដែរឬទេ?

អ្នកអភិវឌ្ឍហ្គេម៖ Raptisoft

ទំហំ៖ ~30 MB



## Cash Cow: Anniversary Edition

**ដំណើរប្រមូលកាក់ដ៏លំបាក!**

តើលោកអ្នកចូលចិត្តលេងហ្គេមនៅកសិដ្ឋានដែរឬទេ? ហ្គេមនេះមានលក្ខណៈពិសេសក្នុងការលេងដោយសារតែវាភ្ជាប់ជាមួយនឹងលក្ខណៈពិសេសជាច្រើនកាន់តែសម្បូរបែប។ ហ្គេមនេះភ្ជាប់ជាមួយនឹងរូបភាពក្រាហ្វិកស្រស់ស្អាត ការទ្រទ្រង់ Game Center សម្រាប់ជំនួយដល់ការលេងហ្គេមដែលជួយលោកអ្នកឈ្នះឈរនៅចំណាត់ថ្នាក់កំពូលនៅលើតារាង និងការសម្រេចបានគោលដៅជាច្រើនទៀតមិនធម្មតានោះទេ។ កាន់តែពិសេសទៀតនោះ លោកអ្នកអាចចាប់ផ្ដើមប្រមូលនូវទឹកប្រាក់សម្រាប់ការកសាងកសិដ្ឋានរបស់អ្នកអោយបានកាន់តែទំនើបទាន់សម័យថែមទៀតផង។ ហ្គេម Cash Cow ពិតជាអស្ចារ្យណាស់ ហើយវាថែមទាំងផ្ដល់នូវភាពបំប្លែងថែមទៀតផង។ លោកអ្នកអាចប្រកួតប្រជែងជាមួយនឹងមិត្តភក្ដិ និងមនុស្សជាច្រើនទៀតនៅជុំវិញខ្លួនអ្នកដើម្បីបូកសរុបមើលថាតើអ្នកណាដែលអាចប្រមូលបានកាក់ច្រើនជាងគេនោះ។

អ្នកអភិវឌ្ឍហ្គេម៖ Riverman Media LLC

ទំហំ៖ ~704 MB



## Drop Wizard Tower

**ហ្គេមវិទ្យាសាស្ត្រការពារស៊ុត!**

ទឹកដីដែលអ្នកកំពុងតែរស់នៅកំពុងតែមានការដណ្ដើមយក ហើយលោកអ្នកត្រូវតែប្រឹងប្រែងធ្វើយ៉ាងណាដើម្បីការពារទឹកដីនេះអោយកាន់តែប្រសើរឡើង។ តើហ្គេម Drop Wizard Tower នេះមានលក្ខណៈពិសេសអ្វីខ្លះទៅ? ហ្គេមនេះគឺលោកអ្នកត្រូវកម្ចាត់នូវបិសាច Shadow Order និងស្វែងរកនូវស៊ុតបុរាណ តើមានអ្វីនៅក្នុងស៊ុតបុរាណនេះ? ហ្គេមនេះក៏អាចលេងបានជាមួយនឹងមិត្តភក្ដិ និងមនុស្សជាច្រើនទៀតនៅជុំវិញពិភពលោក។ តើហ្គេមនេះមានលក្ខណៈពិសេសអ្វីខ្លះទៅ? លោកអ្នកត្រូវធ្វើការផ្សងព្រេងនៅក្នុងវគ្គអាថ៌កំបាំងជាច្រើន និងការប្រើសិល្បៈរួមជាមួយនឹងការប្រយុទ្ធដ៏សាហាវៗជាច្រើនរាប់មិនអស់។ លោកអ្នកនឹងជក់ចិត្តនិតអារម្មណ៍ជាមួយនឹងហ្គេមដ៏អស្ចារ្យនេះជាក់ជាមិនខាន។ តោះនៅចាំអីទៀត!

អ្នកអភិវឌ្ឍហ្គេម៖ Nitrome

ទំហំ៖ 47 MB



## SIEGE: Titan Wars

**មហាសង្គ្រាមបិសាច!**

SIEGE: Titan Wars គឺជាមហាសង្គ្រាមបិសាចដែលលោកអ្នកត្រូវតែប្រយុទ្ធតតល្វែងដើម្បីការពារជីវិត និងទឹកដីរបស់អ្នក។ ហ្គេមនេះតម្រូវអោយលោកអ្នកត្រូវប្រមូលនូវ Cards ជាច្រើនដើម្បីកម្ចាត់នូវសត្រូវរបស់អ្នកតាមរយៈការប្រើប្រាស់កាតទាំងអស់នេះ។ ការប្រយុទ្ធគ្នានៅក្នុងមហាសង្គ្រាមនេះ លោកអ្នកត្រូវប្រើប្រាស់យុទ្ធសាស្ត្រថ្មីៗ និងការគិតអោយបានច្បាស់លាស់ដើម្បីអាចឈ្នះសត្រូវបានយ៉ាងងាយស្រួល។ ហ្គេមនេះភ្ជាប់ជាមួយនឹងការប្រកួតជាលក្ខណៈ Multiplayer និងការប្រមូលកាតដើម្បីយកមកប្រើប្រាស់សម្រាប់ការឡើង Levels ផងដែរ។ លោកអ្នកក៏អាចបង្កើតនូវ Clan សម្រាប់ចែករំលែក Cards និងការបង្កើតនូវសហគមន៍ SIEGE: Titan Wars ទៀត។ កាន់តែពិសេសនោះ លោកអ្នកអាចធ្វើការទស្សនាសារឡើងវិញនូវការប្រកួតរបស់អ្នក និងយុទ្ធសាស្ត្ររបស់គូប្រកួតប្រជែងមុនពេលដែលអ្នកចាប់ផ្ដើមមហាសង្គ្រាមនេះ។

អ្នកអភិវឌ្ឍហ្គេម៖ Game Alliance

ទំហំ៖ ~226 MB



## Epic Little War Game

**កំពូលអ្នកចម្បាំងដ៏ក្លាហាន!**

Epic Little War Game គឺជាប្រភេទហ្គេមយុទ្ធសាស្រ្តធ្វើសង្គ្រាមដ៏អស្ចារ្យដែលមានវគ្គប្រយុទ្ធសប្បាយៗជាច្រើនដែលលោកអ្នកនឹកស្មានមិនដល់នោះទេ។ ហ្គេមនេះពិតជាអស្ចារ្យណាស់នៅក្នុង Single Player Mode ដែលលោកអ្នកអាចប្រយុទ្ធបាញ់ប្រហារដ៏សប្បាយរីករាយ និងការកម្សាន្តគ្មានដែនកំណត់នោះទេ។ លោកអ្នកអាចបង្កើតនូវទីតាំងផ្ទាល់ខ្លួនសម្រាប់ឈរជើង និងការទប់ទល់ជាមួយនឹងសត្រូវដែលចូលមកឈ្លានពានទីតាំងរបស់អ្នកផងដែរ។ អ្វីដែលកាន់តែពិសេសជាងនេះទៀតនោះ ហ្គេមដ៏អស្ចារ្យនេះភ្ជាប់ជាមួយនឹងវគ្គថ្មីៗជាច្រើន រួមទាំងការប្រកួតនៅលើអនឡាញបានផងដែរ។ នៅពេលដែលលោកអ្នកប្រយុទ្ធឈ្នះដៃគូសត្រូវជាច្រើននោះ លោកអ្នកអាចសាងកេរ្តិ៍ឈ្មោះនៅលើ Leaderboard ដើម្បីបង្ហាញពិភពលោកទាំងមូលអំពីសមត្ថភាពដ៏ខ្លាំងក្លា និងការប្រយុទ្ធដ៏ឈ្លាសវៃរបស់អ្នក៕

អ្នកអភិវឌ្ឍហ្គេម៖ Rubicon

ទំហំ៖ ~126 MB



## Mini DAYZ – Survival Game

**ការបង្ហូរឈាមដើម្បីអាយុជីវិត!**

តើលោកអ្នកអាចចំណាយពេលយូរប៉ុណ្ណានៅក្នុងការធ្វើសង្គ្រាមនោះ? ជាមួយនឹងហ្គេម Mini DAYZ – Survival Game លោកអ្នកនឹងទទួលបានអារម្មណ៍ប្លែកមួយទៀតនៅក្នុងការលេងហ្គេមកាន់តែសម្បូរបែបដោយសារតែវាហ្គេមនេះមានអ្នកលេងច្រើនជាង 3 លាននាក់ ហើយវាមិនមានការចំណាយទឹកប្រាក់អ្វីនោះទេ។ ហ្គេមនេះភ្ជាប់ជាមួយនឹងលក្ខណៈពិសេសជាច្រើនទៀតដែលលោកអ្នកអាចបាញ់ប្រហារនៅក្នុងតំបន់ទីតាំងជាច្រើននៅលើពិភពលោក ហើយជាពិសេសលោកអ្នកអាចជ្រើសរើសនូវតួអង្គជាច្រើនទៀតសម្រាប់បន្តដំណើរទៅមុខជាបន្តទៀត។ អ្វីដែលកាន់តែពិសេសទៀតនោះ ហ្គេមនេះភ្ជាប់ជាមួយនឹងលក្ខណៈពិសេសៗជាច្រើនដែលសុទ្ធតែជាវគ្គគ្រោះថ្នាក់ និងឧបសគ្គរាប់មិនអស់៕

អ្នកអភិវឌ្ឍហ្គេម៖ Bohemia Interactive a.s.

ទំហំ៖ ~65 MB



## YANKAI'S PEAK

**បេសកកម្មតំរៀបពីរ៉ាមីត!**

YANKAI'S PEAK គឺជាប្រភេទហ្គេមអាថ៌កំបាំងថ្មីមួយទៀតហើយសម្រាប់អ្នកដែលចូលចិត្តការសាងសង់នូវប្រាសាទពីរ៉ាមីតនោះ។ ហ្គេមដ៏អាថ៌កំបាំងនេះភ្ជាប់ជាមួយនឹងលក្ខណៈនៃការប្រើប្រាស់កាន់តែសម្បូរបែប ហើយវាមានពណ៌ចម្រុះគ្នាគួរអោយចង់លេងខ្លាំងណាស់។ អ្វីដែលកាន់តែពិសេសជាងនេះទៀតនោះ ហ្គេមនេះមានក្រាហ្វិកទាក់ទាញយ៉ាងស្រស់ស្អាត និងមានវគ្គធំៗច្រើនជាង 130 ដែលលោកអ្នកមិនគួរមើលរំលងនោះទេ។ហ្គេមនេះមាន7ផ្នែកធំៗដែលលោកអ្នកត្រូវឆ្លងកាត់ និងការដាក់ចិត្តថានឹងសម្រេចនូវអាថ៌កំបាំងនេះអោយបាន។ តើលោកអ្នកមានសង្ឃឹមប៉ុន្មានភាគរយថាអាចយកឈ្នះអាថ៌កំបាំងនេះនោះ? បើមើលតាមតែសម្បកក្រៅរបស់ហ្គេមនេះប្រហែលជាមិនមានអ្វីដែលគួរអោយពិបាកនោះទេ ប៉ុន្តែនៅពេលដែលចូលលេងផ្ទាល់នោះលោកអ្នកពិតជារំជួលចិត្តជាក់ជាមិនខានឡើយ៕

អ្នកអភិវឌ្ឍហ្គេម៖ Kenny Sun

ទំហំ៖ ~85 MB



## Castleparts

**ការពារទឹកដី គឺដើម្បីការពារអាយុជីវិត!**

ហ្គេមបូរាណដែលទទួលបានការពេញនិយមបំផុតកាលពីជំនាន់សម័យមុននេះ ឥឡូវនេះបានបង្ហាញវត្តមានថ្មីជាមួយនឹងការនាំយកនូវវគ្គថ្មីៗជាច្រើនសម្រាប់ការប្រកួតយុទ្ធសាស្រ្តកាន់តែសម្បូរបែប។ ហ្គេមនេះលោកអ្នកត្រូវសាងសង់អាណាចក្រដ៏ធំមួយដើម្បីការពារពីការឃាររឃីរបស់គូរសត្រូវ ហើយការសាងសង់នេះក៏ជួយការពារនូវជីវិតរបស់លោកអ្នកផងដែរ។ ហ្គេមដ៏អស្ចារ្យនេះភ្ជាប់ជាមួយនឹង Battle Modes រួមទាំង Creep Mode ដែលផ្តល់នូវការប្រយុទ្ធអស្ចារ្យគ្មានដែនកំណត់នោះទេ។ ការប្រកួតនៅក្នុងហ្គេមនេះជាប្រភេទការផ្សងព្រេង ដូចនេះលោកអ្នកមិនអាចធ្វើដំណើរហើយនៅឈប់ស្ងៀមនោះទេ។ ការប្រយុទ្ធនៅក្នុងហ្គេមមួយនេះហាក់ដូចជានាំយកលោកអ្នកទៅកាន់ពិភពបូរាណមួយដែលមានការស្រាវជ្រាវ និងការគិតអោយបានច្បាស់លាស់មុននឹងចាប់ផ្តើមធ្វើដំណើរទៅកាន់វគ្គថ្មីមួយទៀតនោះ៕

អ្នកអភិវឌ្ឍហ្គេម៖ Matthew Olsen

ទំហំ៖ ~94 MB

# Pro Cycling Manager Season 2017

## កំពូលអ្នកគ្រប់គ្រងជើងឯកប្រណាំងកង់



PRO CYCLING MANAGER 2017 គឺជាប្រភេទហ្គេមកីឡាស៊េរីថ្មីប្រចាំឆ្នាំ 2017 នេះដែលទទួលបានការពេញនិយមខ្លាំងពីអ្នកលេងហ្គេម។ ហ្គេមនេះត្រូវអភិវឌ្ឍដោយក្រុមការងារ Cyanide Studio និងចែកចាយស្ថិតនៅក្រោមស្លាកឈ្មោះរបស់ Focus Home Interactive ។

ហ្គេមដ៏អស្ចារ្យនេះអាចលេងបាននៅលើប្រព័ន្ធ ប្រតិបត្តិការ Microsoft Windows និង Platforms ជាច្រើនទៀត។ PRO CYCLING MANAGER 2017 ត្រូវបានដាក់អោយដំណើរការនៅថ្ងៃទី 15 ខែមិថុនា ឆ្នាំ 2017 ។ PRO CYCLING MANAGER 2017 តម្រូវអោយលោកអ្នកក្លាយខ្លួនជាគ្រូបង្វឹកដ៏ឆ្នើមម្នាក់ដើម្បីដឹកនាំក្រុមប្រណាំងកង់ ហើយអ្វីដែលលោកអ្នកត្រូវខិតខំប្រឹងប្រែងនោះគឺយកឈ្នះទៅលើក្រុមប្រណាំងកង់ផ្សេងទៀតដែលសុទ្ធតែជាក្រុមខ្លាំងៗនៅក្នុងការប្រកួតច្រើនជាង 200 លើក។ ការប្រកួតនេះត្រូវធ្វើឡើងនៅជុំវិញពិភពលោកដូចជានៅ Tour de France និង La Vuelta ជាដើម។ បើក្រឡេកមើលទៅកាន់ទេសភាពនៅក្នុងការប្រកួតហ្គេមប្រណាំងកង់នេះវិញពិតជាស្រស់ស្អាតមិនធម្មតានោះទេ លោកអ្នកពិតជាពេញចិត្តពេញថ្លើមជាក់ជាមិនខាន។

នៅក្នុងហ្គេមនេះ លោកអ្នកត្រូវធ្វើការជ្រើសរើសកីឡាករប្រណាំងកង់ និងជួលបុគ្គលិកសម្រាប់ជួយកិច្ចការងាររបស់លោកអ្នក។ លោកអ្នកត្រូវធ្វើការចរចារបង្កើតកុងត្រាជាមួយនឹងបុគ្គលិក និងកីឡាករប្រណាំងទាំងអស់ផងដែរ។ PRO CYCLING MANAGER 2017 ក៏មានប្រើប្រាស់នូវ Pro Cyclist Mode ដែលលោកអ្នកអាចប្រើប្រាស់នូវវត្ថុជាច្រើនផ្សេងៗសម្រាប់ការប្រកួតរបស់លោកអ្នក។ បន្ថែមពីនេះទៀត ហ្គេមដ៏អស្ចារ្យនេះភ្ជាប់ជាមួយនឹងប្រព័ន្ធសំឡេងលឺច្បាស់ និងក្រាហ្វិកស្រស់ស្អាតគ្មានគូប្រៀបនោះទេ។ យើងធានាថាលោកអ្នកពិតជាជក់ចិត្តជាក់ជាមិនខាននៅពេលដែលបានលេងហ្គេមនេះ!

**ព័ត៏មានអំពីហ្គេម**

អ្នកអភិវឌ្ឍហ្គេម៖ Cyanide Studio
អ្នកចែកចាយ៖ Focus Home Interactive
ប្រភេទ Platform៖ Microsoft Windows
ថ្ងៃចេញផ្សាយ៖ 15 មិថុនា 2017
ប្រភេទហ្គេម៖ Simulation / Sports
Mode៖ Single-player / Multi-player

**តម្រូវការប្រព័ន្ធ**

ប្រព័ន្ធប្រតិបត្តិការ៖ Windows 7, Windows 8, Windows 10
អង្គប្រតិបត្តិការ៖ Intel quad-core 3.5 GHz
មេម៉ូរី៖ 8 GB
ក្រាហ្វិកកាត៖ 1 GB, AMD Radeon HD 7850/NVIDIA GeForce GTX 560
ទំហំហ្គេម៖ ~ 11 GB



# MotoGP™17

## កំពូលជើងឯកប្រណាំងម៉ូតូ

MotoGP™17 គឺជាហ្គេមប្រណាំងម៉ូតូថ្មីដែលដាក់អោយដំណើរការនៅជុំវិញពិភពលោកនៅថ្ងៃទី15 ខែមិថុនា ឆ្នាំ2017នៅលើប្រព័ន្ធប្រតិបត្តិការ Microsoft Windows ។ ហ្គេមស៊េរីថ្មីនេះត្រូវបានអភិវឌ្ឍន៍ និងចែកចាយតាមរយៈក្រុម Milestone S.R.L ហើយវាពិតជាអស្ចារ្យខ្លាំងណាស់ក្នុងការកម្សាន្ត។ MotoGP™17 ផ្តល់នូវការប្រកួតជាច្រើនវគ្គដ៏អស្ចារ្យដោយសារតែហ្គេមនេះនាំយកនូវម៉ូតូប្រភេទថ្មីៗ ការប្រកួតនៅជុំថ្មីៗ និងក្រុមជាច្រើនទៀតដើម្បីធ្វើយ៉ាងណាអោយលោកអ្នកទទួលបាន



ពានរង្វាន់ Championship។ ហ្គេមស៊េរីថ្មីនេះភ្ជាប់ជាមួយនឹងមុខងារ Managerial Career Mode ដែលលោកអ្នកអាចធ្វើជាអ្នកគ្រប់គ្រងនៅក្នុងក្រុមនេះបានផងដែរ។

នៅក្នុងការប្រកួតនីមួយៗលោកអ្នកគឺជាអ្នកសម្រេចចិត្តដោយផ្ទាល់ ហើយអ្វីដែលកាន់តែពិសេសជាងនេះទៀតនោះហ្គេមនេះពិតជាមានក្រាហ្វិកគួរអោយទាក់ទាញ និងគួរអោយចង់លេងជាទីបំផុតនោះ។ ហ្គេម MotoGP™17 មានភ្ជាប់ជាមួយនឹងប្រព័ន្ធគ្រប់គ្រងហ្គេម និងប្រព័ន្ធ AI ថែមទៀតផង។ ហ្គេម MotoGP™17 គឺពោរពេញដោយការកម្សាន្ត និងភាពរីករាយបំផុតហើយលោកអ្នកអាចរើសយកនូវប្រភេទម៉ូតូបានច្រើនដើម្បីប្រណាំងនៅលើផ្លូវជាច្រើនដ៏គួរអោយទាក់ទាញ។

តើហ្គេម MotoGP™17 មានលក្ខណៈពិសេសអ្វីខ្លះ? ហ្គេម MotoGP™17 មិនត្រឹមតែមានភាពអស្ចារ្យនៅក្នុងការប្រកួតកីឡា និងការប្រណាំងនោះទេ ប៉ុន្តែហ្គេមនេះមានវគ្គ Championship ជាច្រើនរួមទាំង Managerial Career Mode ដែលមានក្រាហ្វិកដ៏អស្ចារ្យ និងប្រព័ន្ធសំឡេងល្អពិរោះរងំរណ្តំចិត្ត។ តើលោកអ្នកនៅរង់ចាំអ្វីទៀត? តោះ! ទាញយកហ្គេមស៊េរីថ្មីនេះលេងទាំងអស់គ្នា៕

**តម្រូវការប្រព័ន្ធ**

ប្រព័ន្ធប្រតិបត្តិការ៖ Windows® 7 SP1 64-Bit / Windows® 8 64-Bit / Windows® 8.1 64-Bit / Windows® 10

អង្គប្រតិបត្តិការ៖ Intel Core i5 4670K 3.4 GHz / AMD FX-9590 4.7 GHz

មេម៉ូរី៖ 8 GB

ក្រាហ្វិកកាត៖ GeForce GTX 970 / AMD Radeon R9 390 4GB

ទំហំហ្គេម៖ ~33GB

**ព័ត៌មានពីហ្គេម**

អ្នកអភិវឌ្ឍហ្គេម ៖ Milestone S.r.l.

អ្នកចែកចាយ ៖ Milestone S.r.l.

ប្រភេទ Platform ៖ Microsoft Windows

ថ្ងៃចេញផ្សាយ ៖ 15 មិថុនា 2017

ប្រភេទហ្គេម៖ Racing / Simulation / Sports






# SAMSUNG J5 PRO ប្លែកភ្នែកជាមួយរចនាបថថ្មី

ស្មាតហ្វូនម៉ាកល្បី Samsung បានដាក់បង្ហាញស្មាតហ្វូន Update ស៊េរី J ដ៏ទំនើបដើម្បីបំពេញកង្វះខាតដែលមាននៅក្នុងជំនាន់មុន។ ដោយសារតែស្មាតហ្វូនត្រកូល J នេះជាស្មាតហ្វូនដែលទទួលបានការគាំទ្រខ្លាំង ហេតុនេះទើប Samsung ចាំបាច់ត្រូវប្រើឈ្មោះដដែល ប៉ុន្តែដាក់បង្កើនសមត្ថភាពទៅលើប្រព័ន្ធ Hardware និងកម្មវិធីប្រើប្រាស់នៅខាងក្នុង។ សូមស្វាគមន៍ចំពោះវត្តមានរបស់ Samsung Galaxy J5 (2017) សារជាថ្មីម្តងទៀត និងស្វែងយល់ពីភាពខុសគ្នារបស់វាខាងក្រោមនេះ។

**ប្រើប្រាស់រូបរាង និងមុខងារថ្មីទាំងស្រុង**

តើអ្នកធ្លាប់រំពឹងទុកទេថានឹងទទួលបានស្មាតហ្វូនដែលមានរូបរាងដ៏ល្អឥតខ្ចោះពី Samsung ដែរឬទេ? បើដូច្នេះមែនគឺក្នុងពេលនេះអ្នកអាចសម្រេចបំណងរបស់អ្នកបានហើយ ពីព្រោះសម្រាប់ជំនាន់ថ្មីមួយនេះគឺបានផ្តល់ជូនជាមួយរូបរាងដ៏ស្រស់ស្អាតប្លែកជាងមុន និងមានសុវត្ថិភាពជាងមុនផងដែរ។ រីឯនៅផ្នែកខាងមុននៃទូរស័ព្ទនេះគឺមានប្រើប្រាស់នូវប៊ូតុងតែមួយគត់គឺប៊ូតុង Home ហើយវាក៏មានមុខងារជា Sensor សម្រាប់ស្កេនក្រយៅដៃដើម្បីផ្តល់សិទ្ធិដល់អ្នកអាចចូលទៅដំណើរការវាបានផងដែរ ចំណែកឯផ្នែកខាងក្រោយរបស់វាវិញគឺនៅតែប្រើប្រាស់ប្រព័ន្ធកាមេរ៉ាដដែល ប៉ុន្តែ Sensor ថតរូបរបស់វាត្រូវបានផ្លាស់ប្តូរទីតាំងទៅកាន់ទីតាំងកណ្តាលផ្នែកខាងលើម្តងវិញ។

**ប្រើអេក្រង់ទាំងធំ ទាំងស្រស់ស្អាត**

ប្រើប្រាស់អេក្រង់ Super AMOLED ទំហំ 5.2 អ៊ីញ គឺមានន័យថាទូរស័ព្ទនេះមានអេក្រង់ធំ ហើយអាចបង្ហាញបានស្រស់ស្អាតជាងស្មាតហ្វូនកាលពីឆ្នាំ 2015 ទាំងស្រុងតែម្តង។ ម្យ៉ាងទៀត






សម្រាប់តំបន់នៃអេក្រង់របស់វាក៏មានទំហំទូលាយជាងមុនដែរ ដោយលើកនេះអេក្រង់របស់វាគឺលាតសន្ធឹងរហូតទៅដល់គែមសងខាងរបស់វាតែម្តងហើយ។ អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺ J5 (2017) នេះក៏ប្រើប្រាស់ Resolution ប្រសើរជាង (720 x 1280 ភីចសែល) ដែរដើម្បីធ្វើឱ្យផ្ទាំងដែលបានបង្ហាញឡើងមានភាពទាក់ទាញខ្លាំងនោះ។

## កាន់តែមានភាពស្រួល និងផ្តល់ល្បឿនលឿនជាងមុន

ចំណែកឯប្រព័ន្ធ OS Samsung គឺបាន upgraded ពី Android v5.1 Lollipop មកប្រើ Android v7.1 (Nougat) វិញដើម្បីផ្តល់ភាពទាក់ទាញ និងបង្កើនបទពិសោធន៍ប្រើប្រាស់ឱ្យកាន់តែសាមញ្ញបន្ថែមទៀតនោះ។ ម្យ៉ាងវិញទៀតគឺចំពោះបន្ទះ Processor ក៏បាន upgraded ដែរពោលគឺវាបានប្តូរមកប្រើ Processor ដែលមានល្បឿនដំណើរការ 1.6 GHz ប្រភេទ Octa-core Exynos 7870 Octa វិញនិងមាន RAM ទំហំ 2 GB ព្រមជាមួយនឹងទំហំផ្ទុកទិន្នន័យអចិន្ត្រៃយ៍ទំហំ 16 GB ថែមទៀតផង។ ប្រសិនបើអ្នកគិតថាវាមិនគ្រប់គ្រាន់សម្រាប់អ្នកនោះគឺអ្នកអាចជ្រើសរើសយកជម្រើសទីពីរក៏បានដែរ ដោយក្នុងជម្រើសនេះគឺវាប្រើប្រាស់ RAM ទំហំ 3GB និង Memory ទំហំ 32GB។ ហើយបើនៅតែមិនអាចផ្ទុកគ្រប់គ្រាន់ទៀតនោះ អ្នកអាចដាក់បន្ថែមដោយខ្លួនឯងទៀតក៏បានដែរ ពីព្រោះវាបាន Built-in នូវរន្ធ micro SD ដែលអាចបន្ថែមទំហំបានរហូតដល់ទៅទំហំ 256 GB ឯណោះ។

## ចែករំលែកភាពស៊ីវីឡៃជាមួយប្រព័ន្ធកាមេរ៉ាដ៏ទំនើប

ទាំងផ្នែកខាងមុខ និងផ្នែកខាងក្រោយគឺត្រូវបានដាក់ឱ្យប្រើប្រាស់នូវប្រព័ន្ធចាប់យករូបភាពទំហំ 13 មេហ្គាភីចសែលដូចគ្នា គ្រាន់តែថានៅផ្នែកខាងក្រោយមានដំណើរដោយប្រព័ន្ធ Autofocus និងប្រព័ន្ធ Flash LED បន្ថែម។ ជាមួយគ្នានេះដែរគឺវាក៏ Support ផងដែរនូវបណ្តុំមុខងារប្រើប្រាស់ដ៏ទំនើបៗនៅពេលថត។




### ព័ត៌មានមូលដ្ឋាន

**វិមាត្រ :**
ទំហំ : 146.2 x 71.3 x 8 mm
ទម្ងន់ : 162 g

**អេក្រង់ :**
ប្រភេទ : Super AMOLED touchscreen
ទំហំ : 5.2 អ៊ីង, 720 x 1280 pixels ~282 ppi

**អង្គប្រតិបត្តិការ :**
**CPU:** Octa-core 1.6 GHz Cortex-A5
**RAM :** 3 GB RAM - Pro edition

**កាមេរ៉ា :**
ក្រោយ : 13 MP, f/1.7
មុខ : 13 MP, f/1.9

**ប្រព័ន្ធដំណើរការ :**
**OS :** Android 7.1 (Nougat)

**ការតភ្ជាប់ :**
**WLAN :** Wi-Fi 802.11 a/b/g/n/ac, dual-band, WiFi Direct, hotspot
**Bluetooth :** 4.1, A2DP
**GPS :** Yes, with A-GPS, GLONASS, BDS
**NFC :** Yes **Radio :** FM radio
**USB :** microUSB 2.0

**ពណ៌ :** Blue, Pink, Gold, Black




# HUAWEI HONOR 6A
## បំពាក់មុខងារពិសេសៗជាច្រើន

ដើម្បីទទួលបានភាពល្បីល្បាញបន្ថែមលើស៊េរី Honor ក្រុមហ៊ុនផលិតទូរស័ព្ទ Huawei បានបង្កើតសមាជិកថ្មីមួយទៀតហើយ។ ដោយជំនាន់ថ្មីមួយនេះគឺមិនធ្វើឱ្យអ្នកតូចចិត្តនោះឡើយ ដូចអ្វីដែលអ្នកធ្លាប់បានជឿទុកចិត្ត Huawei តាំងពីដើមឡើយអ៊ីចឹង។ ស្វែងយល់ទាំងអស់គ្នាថាថាតើ Huawei Honor 6A មានអ្វីប្លែកសម្រាប់អ្នក។

### ប្រើប្រាស់ទំហំស្តង់ដារ

នៅលើរូបរាងកាយរបស់វាគឺមានភាពស្រស់ស្អាត និងទាន់សម័យខ្លាំងណាស់ ពីព្រោះបើមើលទៅគឺវាស្រដៀងគ្នានឹងស្មាតហ្វូនរបស់ Android



និង IOS ដែរ។ Huawei Honor 6A បានផ្តល់ជូនជាមួយនឹងទំហំប្រើប្រាស់ជាក់ស្តែង 143.7 x 71 x 8.2mm ហើយមានទម្ងន់ត្រឹមតែ 143 ក្រាមប៉ុណ្ណោះ។

### ប្រើប្រាស់អេក្រង់ដ៏មានគុណភាព

ស្មាតហ្វូនស៊េរីថ្មី Huawei Honor 6A នេះដែរគឺបានបំពាក់ឱ្យប្រើប្រាស់មកជាមួយនឹងអេក្រង់ប្រភេទ Touchscreen IPS LCD ទំហំ 5.0 អ៊ីញ ដែលផ្ទៃអេក្រង់របស់វានេះលាតសន្ធឹងប្រហែល 70% ទៅហើយនៃទំហំទូរស័ព្ទទាំងមូលនោះ។

### ផ្តល់ល្បឿនលឿន ហើយផ្ទុកទិន្នន័យឥតដែនកំណត់

ល្បឿនដំណើរការគឺជារឿងដែលសំខាន់សម្រាប់ស្មាតហ្វូននីមួយៗ ហេតុដូចនេះទើប Huawei Honor 6A មានដំណើរការនូវ Processor Qualcomm MSM8937 Snapdragon 430 ដែលមានល្បឿន 1.5 GHz នៅខាងក្នុងនោះ។ ទន្ទឹមនឹងនេះដែរវាក៏បាននាំមកជាមួយផងដែរនូវ RAM ទំហំ 3GB រួមជាមួយនឹង Memory អចិន្ត្រៃយ៍ ទំហំ 16GB ផងដែរ។

### ផ្តល់ទំហំកាមេរ៉ាគ្រប់គ្រាន់សម្រាប់ការថតរូបកម្សាន្ត

នៅផ្នែកខាងក្រោយនៃស្មាតហ្វូនដ៏ទំនើបមួយនេះ គឺបានបំពាក់ឱ្យប្រើប្រាស់ទៅដោយប្រព័ន្ធកាមេរ៉ាទំហំ 13 មេហ្គាភីចសែល ដំណើរការរួមគ្នាជាមួយនឹងប្រព័ន្ធ Flash LED និងប្រព័ន្ធចាប់យករូបភាពស្វ័យប្រវត្តិដើម្បីជួយឱ្យអ្នកអាចថតរូបភាពបានយ៉ាងច្បាស់ និងរហ័សបំផុត។ ចំណែកឯផ្នែកខាងមុខវិញគឺក៏មានប្រើប្រាស់ Sensor សម្រាប់ចាប់យករូបភាពទំហំ 5 មេហ្គាភីចសែលផងដែរ។

### ផ្តល់មុខងារប្រើប្រាស់ដ៏សម្បូរបែប

Huawei Honor 6A ដំណើរការដោយប្រព័ន្ធប្រតិបត្តិការចុងក្រោយ v7.0 (Nougat) របស់ Android ហើយបាន Built-in ដោយប្រព័ន្ធ Wi-Fi ប្រភេទ 802.11 b/g/n មានប្រើប្រាស់ប្រព័ន្ធ Bluetooth 4.1 ប្រព័ន្ធ GPS និង Support ល្បឿនប្រើប្រាស់អ៊ីនធឺណេត 4G LTE ថែមទៀតផង។ ប្រើប្រាស់ជាមួយនឹងទូរស័ព្ទមួយនេះគឺអ្នកនឹងទទួលបានទាំងភាពងាយស្រួលក្នុងការប្រើប្រាស់រួមទាំងមុខងារប្រើប្រាស់ទំនើបៗទៀតផង៕

## ព័ត៌មានមូលដ្ឋាន

**វិមាត្រ :**
ទំហំ : 143.7 x 71 x 8.2 mm
ទម្ងន់ : 143 g

**អេក្រង់ :**
ប្រភេទ : IPS LCD Display
ទំហំ : 5 អ៊ីង, 720 x 1280 pixels ~294 ppi

**អង្គប្រតិបត្តិការ :**
**CPU :** Octa-core 1.5 GHz Cortex-A5
**RAM :** 3GB

**កាមេរ៉ា :**
ក្រោយ : 13 MP, 28mm
មុខ : 5 MP

**ប្រព័ន្ធដំណើរការ :**
**OS :** Android 7.0

**ការតភ្ជាប់ :**
**WLAN :** Wi-Fi 802.11 b/g/n, hotspot
**Bluetooth :** 4.1, A2DP, LE
**GPS :** Yes, with A-GPS, GLONASS
**Radio :** FM radio
**USB :** microUSB 2.0

**ពណ៌ :** Gold, Silver, Blue, Pink




# ស្វែងយល់ពីភាពអស្ចារ្យរបស់ HTC DESIRE 555

HTC ទើបតែបានដាក់បង្ហាញស្មាតហ្វូនស៊េរីថ្មី HTC Desire 555 បន្ទាប់ពីបាត់មុខជាច្រើនខែកន្លងទៅនេះ។ ហើយលើកនេះគឺ HTC បាននាំមកជាមួយនឹងទូរស័ព្ទស្មាតហ្វូនដែលមានប្រព័ន្ធដំណើរការខ្លាំង និងបំពាក់ឱ្យប្រើប្រាស់នូវ Software ដ៏ទំនើបៗ ហើយមានមានអេក្រង់ធំទូលាយងាយស្រួលប្រើប្រាស់ថែមទៀតផង។

### ប្រើប្រាស់ការរចនាជាឧបករណ៍ទាក់ទាញ

HTC Desire 555 មានទំហំតូចល្មម (146.8 x 70.9 x 8.4 mm) ងាយស្រួលកាន់ប្រើប្រាស់ ហើយមានទម្ងន់ស្រាលត្រឹមតែ 140 ក្រាមប៉ុណ្ណោះ។ ចំណែកឯការរចនាវិញ គឺពិតជារចនាបានស្អាតមែនទែន ប៉ុន្តែវាមានតែមួយពណ៌ប៉ុណ្ណោះ (ពណ៌ប្រផេះ) សម្រាប់ជ្រើសរើសប្រើប្រាស់។

### អាចបង្ហាញបានលើសពីរូបរាងរបស់វាទៅទៀត

ប្រើប្រាស់បន្ទះអេក្រង់ទំហំ 5 អ៊ីញដែលមានប្រើប្រាស់ Resolution កម្រិត 720 x 1280 ភីចសែល និងប្រើប្រាស់បច្ចេកវិទ្យាបង្ហាញ TFT នោះគឺមានន័យថា Desire 555 អាចធ្វើឱ្យផ្ទាំងដែលបានបង្ហាញឡើងមានពន្លឺគ្រប់គ្រាន់ ផ្តល់ពណ៌ស្រស់ឆើតឆាយធ្វើឱ្យអ្នកទទួលអារម្មណ៍ថាហាក់ដូចជាកំពុងតែមើលរូបភាពពិតៗ។ បើអ្នកបើកវាសម្រាប់ទស្សនាវីដេអូឬលេងហ្គេមកម្សាន្តគឺរឹតតែប្រសើរ ពីព្រោះវាផ្តល់ទំហំអេក្រង់ធំគួរសមដើម្បីផ្តល់ភាពងាយស្រួលដល់អ្នកបន្ថែមទៀត។

### ប្រើប្រាស់ប្រព័ន្ធប្រើប្រាស់ប្រកបដោយគុណភាព

កុំបារម្ភអីថាស្មាតហ្វូនមួយនេះមានប្រព័ន្ធ Software ស៊េរីចាស់ប្រើប្រាស់ឱ្យសោះនោះ ផ្ទុយទៅវិញគឺវាប្រើ OS Version 7.0 ដ៏ទំនើបរបស់ Android។ ទន្ទឹមនឹងនេះដែរវាក៏បាន Built-in ភ្ជាប់មកជាមួយនឹង Processor Quadcore Qualcomm Snapdragon 210 8909 ដែលផ្តល់ល្បឿនប្រើប្រាស់ 1100 MHz ឯណោះ។

### គ្រប់គ្រាន់សម្រាប់បំពេញតម្រូវការអ្នក

ដើម្បីជួយឱ្យអ្នកអាចផ្ទុកទិន្នន័យកម្សាន្តបានកាន់តែប្រសើរនោះ គឺស្មាតហ្វូនមួយនេះបានផ្តល់ជូន Memory ទំហំ 16 មេហ្គាភីចសែលមកជាមួយស្រាប់ ហើយប្រសិនបើអ្នកចង់បន្ថែមទំហំផ្ទុកបន្ថែមទៀតនោះគឺអ្នកអាចដាក់បន្ថែមបានរហូតដល់ 2000GB ឯណោះ។ ម្យ៉ាងវិញទៀតគឺដើម្បីធ្វើឱ្យល្បឿនដំណើរការអាចដំណើរការបានស្រួល Desire 555 ក៏បានផ្តល់ជូនផងដែរជាមួយនឹង RAM ទំហំ 2GB ទៀតផង។

### ប្រព័ន្ធកាមេរ៉ាបង្កប់ទៅដោយលក្ខណៈពិសេស។

ដោយសារតែកត្តាតំលៃនោះទើប HTC Desire 555 ប្រើប្រាស់ប្រព័ន្ធកាមេរ៉ាទំហំត្រឹម 8 មេហ្គាភីចសែលប៉ុណ្ណោះនៅផ្នែកខាងក្រោយ រីឯផ្នែកខាងមុខវិញគឺវាបានផ្តល់ជូនត្រឹម 5 មេហ្គាភីចសែលនោះទេ។ ក៏ទោះបីជាវាមិនមានទំហំធំដូចប្រព័ន្ធកាមេរ៉ាស្មាតហ្វូនដទៃ តែវាមានមុខងារពិសេសៗដូចគ្នាក្នុងនោះគឺមានមុខងារបញ្ជាថតរូបដោយប្រើសំឡេង មុខងារកំណត់ពេលវេលាក្នុងការថត មុខងារ Zoom ឌីជីថល រួមជាមួយនឹងមុខងារបង្ហាញទីតាំងពីកន្លែងដែលអ្នកបានថតយ៉ាងពិសេសផងដែរ។

### ថាមពល

សម្រាប់ផ្គត់ផ្គង់ថាមពលប្រើប្រាស់នៅខាងក្នុង Desire 555 បំពាក់ដោយថ្មដែលមានកំលាំងថាមពលត្រឹម 2200 mAh ប៉ុណ្ណោះ នេះគឺដោយសារតែវាមានប្រព័ន្ធដំណើរការតិចតួចមិនស៊ីថាមពលខ្លាំង។ ប្រសិនបើអ្នកបើក 3G និយាយគឺអ្នកអាចប្រើប្រាស់បានរហូតដល់ទៅ 13 ម៉ោង ហើយប្រសិនបើអ្នកទុកវា Standby ចោលវិញគឺបានរហូតដល់ទៅ 28 ម៉ោងឯណោះ។ ហេតុនេះទោះបីជាថ្មរបស់វាមានកម្រិតថាមពលតិចសម្រាប់ស្មាតហ្វូនដទៃ តែវាបែរជាសម្បូរបែបសម្រាប់ Desire 555 ទៅវិញ៕




## ព័ត៌មានមូលដ្ឋាន

**វិមាត្រ :**
ទំហំ : 146.8 x 70.9 x 8.4 g
ទម្ងន់ : 140 g

**អេក្រង់ :**
ប្រភេទ : TFT Display
ទំហំ : 5 អ៊ីង, 720 x 1280 pixels ~294 ppi

**អង្គប្រតិបត្តិការ :**
**Processor :** Quad-core, 1100 MHz, ARM Cortex-A7, 32-bit, 28 nm **RAM :** 2 GB

**កាមេរ៉ា :**
ក្រោយ : 8 MP
មុខ : 5 MP

**ប្រព័ន្ធដំណើរការ :**
**OS :** Android 7.1.1 (Nougat)

**ការតភ្ជាប់ :**
**WLAN :** Wi-Fi 802.11 a/b/g/n/ac, dual-band, WiFi Direct, hotspot
**Bluetooth :** 4.1, A2DP, LE, EDR
**GPS :** Yes, with A-GPS, GLONASS
**USB :** microUSB 2.0

**ពណ៌ :** Gray

# HP ZBook 15 G4

## ជាដៃគូការងារថ្មីរបស់អ្នក



ZBook 15 G4 គឺជា Laptop ស៊េរីថ្មីរបស់ HP ដ៏ទំនើបមួយដែលបាននាំមកជាមួយនឹងរូបរាងដ៏ស្រស់ស្អាត បំពាក់ដោយប្រព័ន្ធ Hardware ថ្មីៗដើម្បីធ្វើឱ្យប្រព័ន្ធដំណើរការដើរបានស្រួល ហើយមានប្រព័ន្ធថ្មដែលមានថាមពលខ្លាំងអាចប្រើប្រាស់បានយូរថែមទៀតផង។ បើមើលពីខាងក្រៅនោះអ្នកនឹងឃើញថាកុំព្យូទ័រយួរដៃមួយនេះពិតជាមានរូបរាងដ៏គួរឱ្យ ទាក់ទាញខ្លាំងណាស់ (ទាំងពណ៌ និងការរចនាពិតជាស៊ីគ្នាជាមួយនឹងរូបរាងរបស់មែនទែន) ក្នុងនោះគឺវាមានទំងន់ជិត២គីឡូក្រាមធ្ងន់បន្តិចហើយ ពីព្រោះ HP បានប្រើប្រាស់ Hardware ច្រើនសម្រាប់ Support លើល្បឿនដំណើរការម្យ៉ាងទៀតគឺដោយសារតែវាមានសម្បកការពារផលិតចេញពីលោហៈធាតុថែមទៀតផង





នោះ។ សម្រាប់ការបង្ហាញឯណេះវិញគឺ ZBook 15 G4 បានផ្ដល់ជូននូវអេក្រង់ប្រភេទ DreamColor 4K ដែលមាន Resolution ខ្ពស់ 3840 x 2160 ភីចសែល ទំហំ 15 អ៊ីញដែលអាចផ្ដល់ពន្លឺភ្លឺគ្រប់គ្រាន់ និងផ្ដល់ពណ៌បានស្រស់ស្អាតដូចទៅនឹងពណ៌ពីធម្មជាតិ។ បើធៀបជាមួយនឹង Apple MacBook និង Lenovo ThinkPad P50 គឺពួកវាមិនមានប្រព័ន្ធបង្ហាញដូច ZBook 15 G4 នោះទេ។ អ្វីដែលពិសេសហើយធ្វើឱ្យប្រព័ន្ធដំណើរការរបស់វាកាន់តែប្រសើរឡើងនោះគឺ ZBook 15 G4 នេះបានដាក់ឱ្យដំណើរការជាមួយនឹងបន្ទះផ្ទុកទិន្នន័យទំហំ 512GB ចំនួន 2 និងមានប្រើប្រាស់នូវ Processor ប្រភេទ Intel Xeon E3-1535M ដែលផ្ដល់ល្បឿនប្រើប្រាស់បានរហូតដល់ទៅ 2.9 GHz ឯណោះ លើសពីនេះគឺវាក៏មានប្រើប្រាស់ RAM ទំហំដល់ទៅ 64GB និងមានប្រើប្រាស់បន្ទះក្រាហ្វិចកាត Nvidia Quadro M2200 ទំហំ 4GB ថែមទៀតផង។ ដូចអ្វីដែលបានរៀបរាប់ពីខាងលើអ៊ីចឹងដែរគឺ ZBook 15 G4 ពិតជា Laptop មួយដែលមានប្រព័ន្ធផ្គត់ផ្គង់ថាមពលដ៏មានសមត្ថភាពមួយដែលអាចឱ្យអ្នកប្រើបានជិត 5 ម៉ោងឯណោះ ហើយប្រសិនបើវាអស់ថាមពលវិញគឺអ្នកគ្រាន់តែដោតវាបញ្ចូលថាមពលត្រឹមតែ 30 នាទីប៉ុណ្ណោះនោះអ្នកនឹងទទួលបានថាមពល 50% ត្រលប់មកវិញជាក់ជាមិនខានឡើយ។ ហើយប្រសិនបើអ្នកកំពុងតែស្វែងរក Laptop ដែលមានប្រព័ន្ធដំណើរការខ្លាំង ហើយរហ័សនោះគឺ HP ZBook 15 G4 គឺជាជម្រើសដ៏ល្អសម្រាប់អ្នក ប៉ុន្តែវាមានទំងន់ធ្ងន់ និងឆាប់អស់ថ្មបន្តិចហើយ។





## លក្ខណៈទូទៅ

| | |
|---|---|
| CPU | Xeon E3-1535M v6 (Z2) |
| Operating System | Windows 10 Pro |
| RAM | 64GB |
| RAM Upgradable to | 64GB |
| Hard Drive Size | 512GB |
| Hard Drive Type | NVMe PCIe SSD |
| Secondary Hard Drive | 512GB |
| Secondary HD Type | NVMe PCIe SSD |
| Display Size | 15.6 |
| Highest Resolution | 3840 x 2160 |
| Native Resolution | 3840 x 2160 |
| Graphics Card | NVIDIA Quadro M2200 4GB GDDR5 |
| Video Memory | 4GB |
| Wi-Fi | 802.11ac |
| Wi-Fi Model | Intel Dual band wireless-AC 8265 802.11AC 2x2 WiFi + BT 4.2 Combo Adaptor |
| Bluetooth | Bluetooth 4.2 |
| Touchpad Size | 4.0 x 2.2 inches |
| Ports (excluding USB) | Thunderbolt 3 |
| Ports (excluding USB) | SD card slot |
| Ports (excluding USB) | Kensington Lock |
| Ports (excluding USB) | HDMI |
| Ports (excluding USB) | Audio-in |
| Ports (excluding USB) | VGA |
| USB Ports | 3 |
| Size | 15.2 x 10.4 x 1.0 inches |
| Weight | 5.13 pounds |

# Acer Predator Helios 300

## ជាម៉ាស៊ីន VR Ready ដែលមានតម្លៃទាប ក្នុងចំណោមកុំព្យូទ័រខ្លាំងៗដទៃទៀត




បច្ចុប្បន្ននេះក្រុមហ៊ុនផលិត Laptops ជាច្រើនកំពុងប្រគួតប្រជែងផលិតផលគ្នាលើផ្នែកគុណភាពប្រើប្រាស់ លើផ្នែករចនារូបរាង និងតម្លៃ ក្នុងនោះគឺមានក្រុមហ៊ុនមួយចំនួនបានផ្តល់ជូននូវសមាសធាតុផ្សំថ្មីៗ និងទំនើបទៀតផង ហេតុនេះវាក៏មានតម្លៃថ្លៃបន្តិចដែរ សម្រាប់ក្រុមហ៊ុន Acer វិញគឺផ្តល់ជូននូវតម្លៃដ៏សមរម្យ ហើយមានប្រព័ន្ធ









ដំណើរការប្រហាក់ប្រហែលទៅនឹងកុំព្យូទ័រយួរដៃថ្លៃៗដទៃៗទៀតដែរ។ ត្រកូល Predator គឺតែងតែផ្តល់ជូននូវប្រព័ន្ធអេក្រង់ដែលអាចបង្ហាញបានស្រស់ស្អាតជានិច្ច ហើយក្នុងពេលនេះដែរគឺ Predator Helios 300 បានបំពាក់ទៅដោយផ្ទៃអេក្រង់ធំទូលាយទំហំ 15.6 អ៊ីញ ដែលអាចបង្ហាញបាន 1080p នៃ Resolution Full HD និងអាចផ្តល់ពណ៌បានស្រស់ស្អាតហើយផ្តល់ពន្លឺបានគ្រប់គ្រាន់ ច្បាស់ល្អ ពោលគឺបើនៅលើអេក្រង់មានពន្លឺតិចវានឹងជួយផ្តល់ពន្លឺឱ្យកាន់តែភ្លឺច្បាស់ ហើយប្រសិនបើទីតាំងណាមានពន្លឺខ្លាំងវានឹងជួយបន្ថយពន្លឺ ដើម្បីឱ្យភ្នែករបស់អ្នកទទួលយកបានគ្រប់កាលទេសៈតែម្តង។ ជាមួយនឹងការផ្តល់ជូននូវតម្លៃដ៏សមរម្យ គឺកុំព្យូទ័រ Vr Ready មួយនេះបានដាក់ឱ្យប្រើប្រាស់នូវបន្ទះ GPU ប្រភេទ Nvidia GeForce GTX 1060 ជាមួយនឹង VRAM ទំហំ 6GB ឯណោះ ហេតុដូចនេះមិនថាហ្គេមប្រភេទណានោះទេគឺអ្នកអាចលេងបានដោយមិនបង្ករភាពរអាក់រអួលអ្វីបន្តិចសោះឡើយ ពីព្រោះនៅពេលតេស្តសាកល្បងប្រើប្រាស់ជាក់ស្តែងនោះគឺបានបង្ហាញថា Frame Rate របស់វាស្ថិតនៅចន្លោះពី 80 ទៅ 70 ក្នុងមួយវិនាទី។ មាន GPU ខ្លាំងតែមួយមុខមិនប្រាកដថាអ្នកអាចលេងហ្គេមបានប្រសើរនោះទេដូចនេះ Acer គឺបានភ្ជាប់ឱ្យប្រើប្រាស់បន្ថែមទៀតនូវ Processor ដែលផ្តល់ល្បឿនលឿន (2.8-GHz) ប្រភេទ Core i7-7700HQ ពី Intel បូករួមជាមួយនឹងបន្ទះ RAM ទំហំ 16GB និងបន្ទះ SSD SATA ទំហំ 256GB ផងដែរដើម្បីជាជំនួយដល់ប្រព័ន្ធដំណើរការបន្ថែម។ ជាមួយគ្នានេះដែរសម្រាប់ Gaming Laptop មួយនេះគឺជួយឱ្យអ្នកអាចប្រើប្រាស់បានយូរជាងអ្វីដែល Acer បានរំពឹងទុកទៅទៀតដោយជាក់ស្តែងនោះគឺវាអាចបើកដំណើរការបាន 6 ម៉ោង និង 48 នាទី ហើយដំណើរជាមួយនឹងប្រព័ន្ធប្រតិបត្តិការទំនើបចុងក្រោយរបស់ Window គឺប្រព័ន្ធប្រតិបត្តិការ Window10 ព្រមជាមួយនឹងកញ្ចប់ Software ដែលអ្នកត្រូវការជាចាំបាច់ផងដែរ។ និយាយជារួមទៅគឺ Acer Predator Helios 300 គឺជា VR-ready gaming ម៉ាស៊ីនដ៏មានសមត្ថភាពមួយដែលជួយឱ្យអ្នកចំណេញថវិកាបានច្រើនគួរសមដែរ៕

## លក្ខណៈទូទៅ

| | |
|---|---|
| CPU | 2.8-Ghz Intel Core i7-7700HQ |
| Operating System | Windows 10 Home |
| RAM | 16GB |
| RAM Upgradable to | 32GB |
| Hard Drive Size | 256GB SSD |
| Hard Drive Type | M.2 SATA SSD |
| Display Size | 15.6 |
| Highest Resolution | 1920 x 1080 |
| Native Resolution | 1920x1080 |
| Graphics Card | Nvidia GeForce GTX 1060 / 6GB |
| Video Memory | 6 GB |
| Wi-Fi | 802.11ac |
| Wi-Fi Model | 2x2 MIMO |
| Bluetooth | Bluetooth 4.0 |
| Touchpad Size | 4.1 x 3.0 inches |
| Ports (excluding USB) | Kensington Lock |
| Ports (excluding USB) | USB 2.0 |
| Ports (excluding USB) | USB 3.0 |
| Ports (excluding USB) | USB 3.1 with Type-C |
| Ports (excluding USB) | Ethernet |
| Ports (excluding USB) | HDMI |
| Ports (excluding USB) | Headphone |
| USB Ports | 4 |
| Card Slots | SD memory reader |
| Size | 15.4 x 10.5 x 1.5 inches |
| Weight | 5.47 pounds |

# LENOVO IDEACENTRE 520S-23IKU
## មានអ្វីលើពីការរំពឹងទុកទៅទៀត




សូមស្វាគមន៍ចំពោះការបង្ហាញខ្លួនរបស់កុំព្យូទ័រ all-in-one ស៊េរីថ្មី IdeaCentre 520S-23IKU របស់ Lenovo ដែលបាននាំមកជាមួយនឹងរូបរាងដ៏ស្រស់ស្អាត ទំនើប ដើម្បីជួយលំអតុរបស់អ្នកឱ្យកាន់តែស្រស់ស្អាត និងមានរបៀបរៀបរយ មិនចាំបាច់មានប្រើប្រាស់ខ្សែរញ៉េរញ៉ៃអ្វីនោះទេ។ ជាការពិតណាស់គឺ Lenovo IdeaCentre 520S-23IKU នេះមានទំហំតូចជាងកុំព្យូទ័រ all-in-one ដទៃៗទៀត ប៉ុន្តែវាមានមុខងារប្រើប្រាស់ទំនើបៗ ហើយមានតំលៃសមស្របទៅនឹងអ្វីដែលកុំព្យូទ័រនេះមានប្រើប្រាស់នៅខាងក្នុង នេះហើយជាមូលហេតុដែលធ្វើឱ្យវាមានភាពប្រគួតប្រជែងខ្លាំងនៅលើទីផ្សារនោះ។ ដើម្បីបង្កើនភាពស្រស់ស្អាត Lenovo បានប្រើប្រាស់បន្ទះលោហៈធាតុទាំងស្រុងទៅហើយសម្រាប់ជាសម្បកការពារនៅខាងក្រៅ និងមានទំហំជាក់ស្តែង 20.6 x 12.8 x 1.6 អ៊ីញ មានទម្ងន់ធ្ងន់បន្តិចហើយ (ជិត 5 គីឡូក្រាម) ជាពិសេសនោះគឺវាមានអេក្រង់ដែលអាចឱ្យអ្នកបង្វិលបានរហូតដល់ទៅ 35 ដឺក្រេថែមទៀតផង។ នាពេលបច្ចុប្បន្ននេះចំពោះអេក្រង់ 4K គឺជាប្រភេទអេក្រង់ដែលកំពុងពេញនិយមប្រើប្រាស់បំផុតនៅលើទីផ្សារ ប៉ុន្តែសម្រាប់ IdeaCentre 520S-23IKU មានប្រើប្រាស់អេក្រង់ត្រឹម



តែ full-HD ប៉ុណ្ណោះពីព្រោះដើម្បីកាត់បន្ថយតំលៃនេះឯង។ យ៉ាងណាមិញគឺវាមានអេក្រង់ដែលអាចបង្ហាញបានច្បាស់គ្រប់គ្រាន់ និងមានទំហំធំទូលាយ (23 អ៊ីញ) លាតសន្ធឹងស្ទើរតែពេញរូបរាងទាំងមូលរបស់វាទៅហើយ ហើយថែមទាំង Support ការប៉ះបញ្ជារនៅលើអេក្រង់ដោយផ្ទាល់ទៀតផង។ ចំណែកឯប្រព័ន្ធកូល័រ និងបច្ចេកវិទ្យាផ្តល់ពន្លឺវិញគឺប្រហាក់ប្រហែលទៅនឹងកុំព្យូទ័រ all-in-one iMac របស់ Apple ផងដែរ។ ក្រៅពីមានរូបរាងដ៏គួរឱ្យទាក់ទាញហើយនោះកុំព្យូទ័រ IdeaCentre 520S-23IKU ក៏បានផ្តល់ជូននូវសមត្ថភាពគ្រប់គ្រាន់សម្រាប់ការលេងហ្គេមដែលមានក្រាហ្វិចធំៗ ក៏ដូចជាការប្រើប្រាស់កម្មវិធី 3D ផ្សេងៗផងដែរដែលក្នុងនោះគឺវាបានបំពាក់ឱ្យដំណើរជាមួយនឹង Processor ម៉ូដែល Intel Core i7 ល្បឿន 2.7-GHz ព្រមជាមួយនឹង RAM ទំហំ 8GB ហើយនិងបន្ទះក្រាហ្វិចកាតប្រភេទ Intel HD Graphics 620 ផងដែរនៅខាងក្នុង។ ជ្រើសរើស Lenovo IdeaCentre 520S-23IKU គឺជ្រើសរើសភាពទាន់សម័យសម្រាប់ប្រើប្រាស់ ហើយថែមទាំងផ្តល់ល្បឿនប្រើប្រាស់គួរសមសម្រាប់ដោះស្រាយការងារផ្សេងៗបានច្រើនក្នុងពេលតែមួយ និងមានតម្លៃសមរម្យទៀតផង៕





## លក្ខណៈទូទៅ

| | |
|---|---|
| Hard Drive Capacity | 1000 gigabytes |
| Operating System | Windows 10 |
| Processor Speed | 2.7 gigahertz |
| Processor Model | Intel 7th Generation Core i7 |
| System Memory (RAM) | 8 gigabytes |
| Graphics Card | Intel HD Graphics 620 |
| Screen Resolution | 1920 x 1080 (Full HD) |
| Screen Size | 23 inches |
| Touch Screen | Yes |
| Wireless Keyboard | Yes |
| Wireless Mouse | Yes |
| HDMI Outputs | 1 |
| Port Type(s) | USB 2.0, USB 3.0, HDMI, Ethernet, Headphone |
| Bluetooth Enabled | Yes |
| Multi-Touch Screen | Yes |
| Color | Black/silver |
| Height | 12.8 inches |
| Width | 20.6 inches |
| Depth | 1.6 inches |
| Weight | 9.7 pounds |

# FlipBuilder Flip PDF Professional
## បង្កើតសៀវភៅអេឡិចត្រូនិចត្រឹមតែ១នាទី




ពិតណាស់គឺកម្មវិធី FlipBuilder Flip PDF Professional ជាកម្មវិធីមួយដ៏ជំនាញសម្រាប់បង្កើត Files ដែលមានទម្រង់ជាទំព័រសៀវភៅ ហើយផ្តល់ភាពងាយស្រួលក្នុងការបើកមើលថែមទៀតផង។ ប្រើប្រាស់ជាមួយនឹងកម្មវិធីនេះអ្នកនឹងអាចបង្កើតឯកសារជាទំព័រៗបានយ៉ាងងាយស្រួល ហើយបន្ទាប់មកគឺអ្នកអាចបើកវាប្រើប្រាស់ដូចបើកសៀវភៅអ៊ីចឹង។ ប្រសិនបើអ្នកបើកបង្ហាញវានៅលើ iPad ទូរស័ព្ទ iPhone ទូរស័ព្ទ Android ឬ desktop PCs នោះគឺវាអាចបង្ហាញបានយ៉ាង Smooth ជាទីបំផុត។

### ព័ត៌មានលំអិតរបស់ FlipBuilder Flip PDF Professional

ឈ្មោះកម្មវិធី : FlipBuilder Flip PDF Professional
ឈ្មោះ File Set up : Flip_PDF_Professional_2.4.7.4.zip
ទំហំនៃ File : 285 MB
ប្រភេទនៃការតម្លើង : Offline Installer / Full Standalone Setup
លទ្ធភាពនៃការតម្លើង: 32 Bit x86/ 64 Bit x64
ថ្ងៃចេញ Version ចុងក្រោយ: 13th Feb 2017
បង្កើតដោយ : FlipBuilder

### លក្ខណៈពិសេសៗនៃ FlipBuilder Flip PDF Professional

- កម្មវិធីដ៏មានជំនាញសម្រាប់បង្កើតទំព័រសៀវភៅ
- មានបំពាក់នូវ Templates ស្រស់ស្អាតជាច្រើន
- អាចកែតម្រូវបានច្រើនជម្រើស
- អាចបញ្ចូលប្រព័ន្ធមេឌាផ្សេងៗជាច្រើនបាន
- ល្អបំផុតសម្រាប់ការបង្កើតទស្សនាវដ្ដី

### តម្រូវការប្រព័ន្ធក្នុងការតម្លើង FlipBuilder Flip PDF Professional

ប្រព័ន្ធប្រតិបត្តិការ : Windows XP/Vista/7/8/8.1/10
Memory (RAM) : 512 MB of RAM required
ទំហំ Hard Disk នៅសល់ : 50 MB
ល្បឿន Processor : Intel Pentium 4 or later



FlipBuilder Flip PDF Professional ផ្តល់ជូននូវការប្រើប្រាស់ជាច្រើនជម្រើស ដោយជាក់ស្តែងនោះគឺអ្នកអាចផ្លាស់ប្តូរពណ៌នៃទំព័រនីមួយៗ ឬតួអក្សរ ហើយអ្នកក៏អាចកំណត់កម្រាស់របស់ Page ផងដែរ ជាពិសេសនោះគឺអ្នកអាចផ្លាស់ប្តូរស្ទាយ៍នៅពេលបើកពីទំព័រមួយ ទៅទំព័រមួយក៏បាន។ ក្រៅពីនេះ FlipBuilder ក៏បានផ្តល់ជូនឱ្យអ្នកនូវមុខងារពិសេសជាច្រើនទៀត ដូចជា ការបញ្ចូលអត្ថបទបន្ថែម ការបញ្ចូលវីដេអូពី Youtube ឬការបញ្ចូលសំឡេងក៏បានដែរ។ ប្រសិនបើលោកអ្នកកំពុងតែស្វែងរក Software សម្រាប់បង្កើតសៀវភៅ catalogs សៀវភៅ brochures ឬបង្កើតទស្សនាវដ្តីនោះ សូមទាញយកកម្មវិធីនេះប្រើប្រាស់ចុះវានឹងជួយសម្រួលការរបស់អ្នកបានមួយកម្រិតដែរ។

### សេចក្តីណែនាំប្រើប្រាស់

១- បើកវាឱ្យដំណើរការពី icon shortcut នៅលើ Desktop ។

២- បង្កើត Project ថ្មីមួយ។




### ៣- ទាញបញ្ចូល PDF ដែលអ្នកចង់បង្កើត (Import)

ដើម្បីធ្វើដូចនេះសូម Click ប៊ូតុង "Browse.." ដើម្បីស្វែងរកទីតាំងនៃ File PDF ដែលអ្នកត្រូវប្រើការួចចុចលើប៊ូតុង "Import Now"។




### ៤- ធ្វើការកែតម្រូវ Flipbook

បង្កើតឯកសារទំព័រសៀវភៅដោយប្រើប្រាស់ template ប្រើប្រាស់ theme ឬលក្ខណៈជាច្រើនទៀតរួច Click "Apply Change" ។




៥- ប្រសិនបើអ្នកចង់បញ្ចូលប្រព័ន្ធមេឌាសូម Click លើប៊ូតុង "Edit Pages" រួចអ្នកក៏អាចបន្ថែម local video, YouTube, Vimeo, audio, images ទៅកាន់ flipbook។










### ៥- ធ្វើការ Publish ឯកសារអ្នកនៅលើ Flipbook

ដើម្បីធ្វើដូចនេះចូរអ្នក Click លើប៊ូតុង "Upload Online" ឬ Click លើប៊ូតុង Publish ដូចនេះអ្នកអាចធ្វើការបង្ហាញឯកសារអ្នកនៅលើ Web Browser គ្រប់ប្រភេទបាន។






# ស្វែងយល់ពីគន្លឹះផ្សេងៗ ក្នុងការប្រើប្រាស់កុំព្យូទ័រ

## វិធីងាយៗ លេងហ្គេមរបស់ windows ជំនាន់មុន លើ windows 10

## វិធីបិទ Notification និង System Sounds នៅក្នុង Windows 10

# វិធីងាយៗ លេងហ្គេមរបស់ windows ជំនាន់មុន លើ windows 10




Windows 10 គឺជាប្រព័ន្ធប្រតិបត្តិការចុងក្រោយដែលមានមុខងារប្រើប្រាស់ដ៏ទំនើបៗ និងមានផ្ទាំងបង្ហាញប្រើប្រាស់ដ៏ស្រស់ស្អាត ហើយផ្តល់ភាពងាយស្រួលផងដែរក្នុងការប្រើប្រាស់។ ក៏ប៉ុន្តែមានមុខងារចាស់ៗមួយចំនួនតូចដែល Microsoft លាក់មិនអោយអ្នកប្រើប្រាស់បាន តែបែរជាមានផ្ទាំងផ្សាយពាណិជ្ជកម្ម (ads) ជាច្រើនទៅវិញនៅលើប្រព័ន្ធប្រតិតបត្តិការជំនាន់ថ្មីនេះ។ ប្រសិនបើអ្នកចង់ទាញយកមុខងារចាស់ៗ ឬចង់ប្រើប្រាស់កម្មវិធីដែលអ្នកធ្លាប់ប្រើនៅក្នុងប្រព័ន្ធ Window ស៊េរីចាស់យកមកប្រើប្រាស់នៅក្នុង Window ស៊េរីថ្មីនោះ ពេលនេះគឺអ្នកអាចធ្វើបានដោយអ្នកគ្រាន់តែធ្វើតាមជំហានមួយចំនួនខាងក្រោមប៉ុណ្ណោះ។



ចូលទៅទាញយក Windows 7 Games for Windows 10, Windows 8, and Windows 8.1 zip file ពីវ៉ិបសាយ winaero.com។ នៅពេលដែលអ្នកបានចូលទៅដល់ផេកមួយនេះសូមអ្នកកុំ Click លើប៊ូតុង download here (ប៊ូតុងផ្សាយពាណិជ្ជកម្ម) អ្នកត្រូវ Scroll ចុះក្រោមរហូតដល់អ្នកឃើញ Link (Download Window Games for Window 10)មួយដែលស្ថិតនៅផ្នែកខាងក្រោមជិតប៊ូតុង Donate។



Click OK លើផ្ទាំងដែលបានបង្ហាញឡើងដើម្បីធ្វើការ download។




Double-click ទៅលើ File ដែលអ្នកទើបនឹងបានដោនឡូតរួចនោះ ដើម្បី extract សម្រាប់ដំឡើង។




បន្ទាប់មកសូម Double-click លើ file ដែលអ្នកទើបនឹងបាន Extract រួចនោះ។




សូម Click លើប៊ូតុង Yes ដើម្បីឯកភាពក្នុងការដំឡើង។




ជ្រើសរើសភាសាសម្រាប់ប្រើប្រាស់។




សូម Click លើប៊ូតុង Next សម្រាប់ជំហានបន្ទាប់។




សូម Select យកហ្គេមណាមួយ ឬហ្គេមទាំងឡាយណាដែលអ្នកចង់ឱ្យមាន ឬចង់ដំឡើង។




សូម Click ពាក្យថា Install ដើម្បីចាប់ផ្តើមដំឡើង។



# វិធីបិទ Notification និង System Sounds នៅក្នុង Windows 10




Windows notifications (ព័ត៌មានរំឭក) គឺមានតែជាមួយនឹងប្រព័ន្ធប្រតិបត្តិការជំនាន់ថ្មីប៉ុណ្ណោះ ក៏ប៉ុន្តែថាតើអ្នកអាចគ្រប់គ្រងវាដោយរបៀបណា ប្រសិនបើអ្នកគិតថាវាលោតមករំខានអ្នកនៅពេលដែលអ្នកកំពុងតែបំពេញកិច្ចការរបស់អ្នកយ៉ាងស្ងាត់ស្ងៀមនោះ។ ខាងក្រោមនេះជាលំដាប់លំដោយនៃការបញ្ឈប់ Windows notifications ដើម្បីកុំឱ្យវាលោតមករំខានអ្នកបានតទៅទៀត។




សូម Click លើប៊ូតុង notification ដែលស្ថិតនៅផ្នែកខាងក្រោមជ្រុងខាងស្តាំនៃ Screen។



បន្ទាប់មកសូម Click លើ All Settings ប៊ូតុង។




នៅក្នុងផ្ទាំង main Settings នេះសូមអ្នកជ្រើសយកពាក្យ System។




ចូរជ្រើសយក Notifications & actions ដែលស្ថិតនៅក្នុង sidebar ខាងឆ្វេងដៃ។




ដើម្បីបញ្ឈប់ការបិទ (turn off) Notifications ឱ្យបានចប់សព្វគ្រប់ សូមទាញប៊ូតុង Get notifications from apps and other senders ទៅកាន់ទីតាំង Off។




ដើម្បីកំណត់ទៅតាមអ្វីដែលអ្នកចង់បានសូម Scroll ចុះក្រោមដើម្បី Select ឬបិទ Notifications ណាមួយ (banner ឬ sounds) ឬបិទទាំងពីរួមគ្នាក៏បានដែរ។











# តើគេអាចលួចយកគណនីហ្វេសប៊ុករបស់អ្នកបានយ៉ាងដូចម្តេច ?

វិធីសាស្ត្រមួយក្នុងចំណោមវិធីសាស្ត្រជាច្រើននោះ គឺការទាយពាក្យសម្ងាត់របស់អ្នក។ តើហេតុអ្វីបានគេអាចទាយពាក្យសម្ងាត់របស់អ្នកបាន? ពីព្រោះតាមការសង្កេតគឺមានគណនីមួយភាគធំប្រើប្រាស់ពាក្យសម្ងាត់ខ្សោយ (គឺជាពាក្យសម្ងាត់ដែលប្រើប្រាស់ឈ្មោះ លេខទូរស័ព្ទ ឬថ្ងៃ ខែ ឆ្នាំកំណើតជាដើម) ។

ដើម្បីការពារខ្លួនអ្នក គឺជំហានដំបូងគឺត្រូវប្រើប្រាស់ពាក្យសម្ងាត់ដែលខ្លាំង ដែលវាមានសារៈសំខាន់ណាស់សម្រាប់ការពារមិនឱ្យជនអាក្រក់ជ្រៀតចូលទៅកាន់ប្រព័ន្ធព័ត៌មានរបស់អ្នក មានដូចជាអ៊ីម៉ែល ឬគណនីហ្វេសប៊ុកជាដើម។

**ដូចម្តេចទៅដែលហៅថាពាក្យសម្ងាត់ដែលខ្លាំង ?**

ពាក្យសម្ងាត់ដែលខ្លាំងគឺមានលក្ខណៈដូចខាងក្រោម៖

- មានប្រវែងប្រាំបីតួអក្សរយ៉ាងតិចបំផុត
- មានតួលេខ តួអក្សរ និងតួនិម្មិតសញ្ញាពិសេស
- មិនត្រូវប្រើប្រាស់ឈ្មោះ លេខទូរស័ព្ទ ថ្ងៃខែឆ្នាំកំណើត ឬពាក្យដែលមានន័យត្រឹមត្រូវ (ក្នុងវចនានុក្រម) ឡើយ
- អាចប្រើប្រាស់ជា PassPhrase ជាដើម (ឧ. iwillgoToMarketTomorrow)
- ត្រូវឧស្សាហ៍ផ្លាស់ប្តូរពាក្យសម្ងាត់អ្នកឱ្យបានទៀងទាត់

ឧ. ពាក្យសម្ងាត់ដែលខ្លាំង: 1tsfwi@Win10, Ycl@htw#8675309

**តើពាក្យសម្ងាត់របស់អ្នកខ្លាំងដែលឬទេ ? តើអ្នកធ្លាប់ផ្លាស់ប្តូរពាក្យសម្ងាត់ឬទេ ?**

# តើអ្វីទៅជា Public Key Infrastructure (PKI)?



PKI គឺជាយន្តការមួយក្នុងចំណោមយន្តការជាច្រើនសម្រាប់ពង្រឹងសន្តិសុខនិងសុវត្ថិភាពក្នុងការធ្វើប្រតិបត្តិការអនឡាញ (Online Transaction) មានដូចជា e-commerce, internet banking និង confidential email ជាដើម។ មានបច្ចេកវិទ្យាជាច្រើនដែលត្រូវបានប្រើប្រាស់ដើម្បីបន្ថែមសន្តិសុខ ក៏ប៉ុន្តែសម្រាប់ #PKI គឺមានលក្ខណៈល្អប្រសើរជាងគេនៅក្នុងចំណោមនោះ ដែលបច្ចុប្បន្ននេះមានក្រុមហ៊ុនយក្សធំៗកំពុងតែប្រើប្រាស់នៅក្នុងសេវារបស់ខ្លួនដូចជា Cloud Storage ជាច្រើន។

បច្ចេកវិទ្យានេះគឺជាសំនុំនៃក្បួនច្បាប់ គោលនយោបាយ និងនីតិវិធីដែលត្រូវការសម្រាប់ធ្វើការបង្កើត គ្រប់គ្រង ចែកចាយ ប្រើប្រាស់ រក្សាទុក និងការដកហូតនូវវិញ្ញាបនប័ត្រឌីជីថល (digital certificates) និងការគ្រប់គ្រងទៅលើកូដនីយកម្មកូនសោរសាធារណៈ (public-key encryption)។

វាផ្តោតទៅលើបួន (04) ចំនុចធំៗពាក់ព័ន្ធទៅនឹងសន្តិសុខនិងសុវត្ថិភាព:

១. ផ្ទៀងផ្ទាត់ទៅលើសិទ្ធិរបស់អ្នកប្រើប្រាស់ (User Authentication)
២. សុច្ចរិតភាពនៃប្រតិបត្តិការ (Message Integrity)
៣. ភាពសំងាត់នៃទិន្នន័យ (Encryption)
៤. ភាពមិនអាចប្រកែកបាន (Non-Repudiation)

ទោះបីជាកម្ពុជាមិនទាន់មាននូវហេដ្ឋារចនាសម្ព័ន្ធនេះនៅឡើយក៏ពិតមែន ប៉ុន្តែកម្ពុជានៅតែចូលរួមចំណែកចែករំលែកនូវវឌ្ឍនៈភាពនៃយន្តការនានា ដើម្បីធ្វើឲ្យប្រសើរឡើងនូវសន្តិសុខនិងសុវត្ថិភាពក្នុងការធ្វើប្រតិបត្តិការអនឡាញនៅកម្ពុជា៕






# វិធីសាស្ត្រ ៤ យ៉ាង ដើម្បីស្រោចស្រង់ស្ថានការណ៍ត្រឡប់មកវិញ ក្រោយការវាយប្រហារ Cyber Attack

ត្រៀមឱ្យបានរួចរាល់និងធ្វើសកម្មភាពឱ្យបានលឿន គឺជាកត្តាពីរយ៉ាងដែលនឹងជួយអ្នកស្រោចស្រង់ពីការវាយប្រហារឲ្យបានទាន់ពេលវេលា។ ក្រុមហ៊ុនជាច្រើនបានក្លាយជាជនរងគ្រោះពីការវាយប្រហារតាមអ៊ិនធឺណិត ក្នុងខណៈពេលដែលមេរោគកុំព្យូទ័រ និងបច្ចេកទេសវិស្វកម្មសង្គម (social engineering) កំពុងតែមានការគំរាមគំហែងដល់ព័ត៌មានផ្ទាល់ខ្លួន និងសុវត្ថិភាពអនឡាញកាន់តែមានកើនឡើងឥតឈប់ឈរ ។

ជាមួយនឹងកំណើននៃឧក្រិដ្ឋកម្មតាមប្រព័ន្ធអ៊ិនធឺណិតរៀងរាល់ឆ្នាំ វាមានសារៈសំខាន់ណាស់សម្រាប់ក្រុមហ៊ុនទាំងអស់មាននូវផែនការសង្គ្រោះដើម្បីឆ្លើយតបទៅនឹងការបាត់បង់នានា។ ជាថែដន្យបើសិនជាអង្គភាពទទួលរងការវាយប្រហារលួចទិន្នន័យ (data breach) ខាងក្រោមនេះគឺជាជំហានដែលអ្នកត្រូវធ្វើក្នុងការស្រោចស្រង់សភាពការណ៍មកវិញ ៖

### ១- ធ្វើការកំណត់ទំហំនៃការវាយប្រហារ

ជាមធ្យម ក្រុមហ៊ុនទាំងឡាយគឺមិនបានដឹងអំពីការលួចទិន្នន័យ ឬការវាយប្រហារឡើយរហូតទាល់តែយ៉ាងហោចណាស់ ២០០ថ្ងៃបន្ទាប់ពីវាកើតមានឡើង។ ក្នុងខណៈពេលដែលបានដឹងអំពីបញ្ហានេះហើយ ជំហានដំបូងដែលអ្នកត្រូវធ្វើគឺធ្វើការកំណត់ទំហំនៃបញ្ហា ហើយបន្ទាប់មកកាត់ត្រាព័ត៌មានដូចខាងក្រោម ៖

– តើវាកើតមានឡើងនៅពេលណា?
– តើវាមានផលប៉ះពាល់ទៅដល់អតិថិជនយ៉ាងដូចម្តេច?
– តើទ្រព្យសម្បត្តិយើងមួយណាដែលប៉ះពាល់?
– តើនរណាជាជនរងគ្រោះ?
– តើនេះជាការវាយប្រហារប្រភេទអ្វី?

ដើម្បីកំណត់អំពីទំហំ និងដោះស្រាយបញ្ហា ផ្នែកព័ត៌មានវិទ្យារបស់អង្គភាពអ្នកគួរតែមានភាពរួចរាល់ក្នុងការដាក់ទិន្នន័យសំខាន់ៗឱ្យដាច់ដោយឡែកពី Network, ធ្វើការ reset រាល់គណនីណាដែលប៉ះពាល់ទាំងអស់, ធ្វើការបញ្ចូលឡើងវិញ files ណាដែលប៉ះពាល់, ផ្តាច់ចេញនូវកុំព្យូទ័រណាដែលរងគ្រោះ, លុបចោល files ទាំងឡាយណាដែលបញ្ចូលដោយ Hacker និងធ្វើការជួសជុលកំហុសឆ្គងដោយការធ្វើបច្ចុប្បន្នភាព patches ក្នុងករណីចាំបាច់។

## ២- ជូនដំណឹងទៅដល់អតិថិជន

ក្រុមហ៊ុនធំៗមិនមានប្រវត្តិក្នុងការឆ្លើយតបទៅនឹងការវាយប្រហារបានទាន់ពេលវេលាសមស្របឡើយ។ ក្នុងពេលដែលពួកគេធ្វើការឆ្លើយតបយ៉ាងលឿនទៅនឹងបញ្ហានោះ ជារឿយៗវាត្រូវការពេលរាប់ខែមុនពេលដែលពួកគេធ្វើការប្រកាសជាសាធារណៈ។ ករណីនេះវាអាចឈានទៅដល់ការប្តឹងផ្តល់ ប៉ះពាល់ដល់កិត្តិនាម និងការបាត់បង់អតិថិជនយ៉ាងច្រើនសន្ធឹកសន្ធាប់។

ដំណោះស្រាយគឺថាអ្នកត្រូវមាននូវផែនការឆ្លើយតបមុនពេលដែលមានករណីលួចណាមួយកើតមានឡើង។ ត្រូវធ្វើការទាក់ទងជាមួយនឹងផ្នែកទំនាក់ទំនងសាធារណៈ និងផ្នែកទីផ្សារក្នុងការរៀបចំផែនការទំនាក់ទំនង (communication) ដែលនឹងត្រូវផ្សព្វផ្សាយនៅពេលដែលមានបញ្ហាកើតឡើង ដោយរួមមាន ទាំងព័ត៌មានស្តីពីសំណង និងជំហាននិមួយៗនៃការទប់ស្កាត់ការកើតឡើងសារជាថ្មីម្តងទៀតនាពេលអនាគត។ នៅពេលដែលត្រូវការប្រើប្រាស់វា សូមបញ្ចូលផ្នែក IT របស់អ្នក ដើម្បីបំពេញព័ត៌មានលំអិត ។

## ៣- ទប់ស្កាត់ការវាយប្រហារនាពេលអនាគត

ក្នុងពេលដែលអ្នកបានរងការវាយប្រហារលួចទិន្នន័យ វាសំខាន់ចាំបាច់ណាស់ដែលអ្នកត្រូវតែមានអ្នកជំនាញផ្នែកសន្តិសុខនៅជាមួយអ្នកដើម្បីជួយដល់ការស្រោចស្រង់ដំណើរការអាជីវកម្មរបស់អ្នកវិញ។ យោងទៅតាមក្រុមហ៊ុន IBM បានឲ្យដឹងថា បើសិនជាអ្នកមាននូវក្រុមអ្នកជំនាញផ្នែកសន្តិសុខដូចជានាយកផ្នែកសន្តិសុខព័ត៌មាន អ្នកគ្រប់គ្រងផ្នែកអាជីវកម្ម និងក្រុមឆ្លើយតបឧប្បទេវហេតុសន្តិសុខ នោះវានឹងអាចជួយសន្សំថវិការបស់អ្នកបានរាប់សិនលានដុល្លារ បើសិនជាប្រៀបធៀបជាមួយកិច្ចប្រឹងប្រែងជួសជុល និងឆ្លើយតបទៅបញ្ហាណាមួយ (នៅពេលកើតឡើង)។

ក្រុមហ៊ុនក៏អាចធ្វើការបន្ទាបថ្លៃដើមនៃយន្តការទប់ស្កាត់របស់ខ្លួនដោយវិនិយោគទៅលើបច្ចេកវិទ្យា online security។ អ្នកស្រាវជ្រាវពី Ponemon Institute បានរកឃើញថា ការដែលមានប្រព័ន្ធគ្រប់គ្រងសន្តិសុខទំនើបនឹងអាចជួយដល់ក្រុមហ៊ុនប្រមាណជាមធ្យម ៣.៧លានដុល្លារ ក្នុងខណៈពេលដែលបច្ចេកវិទ្យា Encryption អាចជួយដល់ក្រុមហ៊ុនបាន ១.៤លានដុល្លារក្នុងមួយឆ្នាំ។ ការប្រើប្រាស់ advanced firewalls បានជួយប្រមាណ ២.៥លានដុល្លារ។

## ៤- ត្រៀមការពារតាមផ្លូវច្បាប់ឲ្យបានមុតមាំ

ក្រោយពីទិន្នន័យត្រូវបានលួចពីក្រុមហ៊ុនរបស់អ្នក គឺក្រុមហ៊ុនរបស់អ្នកអាចប្រឈមមុខនឹងពាក្យបណ្តឹង។ ដូចជាករណីក្រុមហ៊ុន Yahoo ដែលរងបណ្តឹងក្នុងករណីដែលទិន្នន័យអតិថិជនប្រមាណជា៥០០លាននាក់ត្រូវបានគេលួចបាន។ ហេតុដូចនេះ វាជាការសំខាន់ណាស់សម្រាប់ឱ្យក្រុមហ៊ុនអ្នកធ្វើការត្រៀមខ្លួនឲ្យបានស្រេច ក្នុងករណីដែលអតិថិជនប្តឹងទៅតុលាការ (ករណីដែលឲ្យហេគឃ័រអាចអាក់សេស (access) ទៅកាន់ព័ត៌មានផ្ទាល់ខ្លួន)។

អ្នកគួរតែបង្កើតនូវទំនាក់ទំនងជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ចមុនពេលដែលបញ្ហាកើតមានឡើង (Point of Contact) ដើម្បីងាយស្រួលនៅពេលដែលមានបញ្ហាកើតឡើង (ថាតើត្រូវទាក់ទងទៅអ្នកណា)។ អ្នកគ្រប់គ្រងគួរតែប្រាកដឲ្យបានច្បាស់ថា ក្រុមនីតិកម្មរបស់ខ្លួនមានបទពិសោធន៍ជាមួយនឹងការគ្រប់គ្រងឧប្បទេវហេតុសន្តិសុខ (cyber incident management) ដោយរួមមាននូវចំណេះដឹងពាក់ព័ន្ធកិច្ចការមួយចំនួនដូចជាការរាយការណ៍ទៅកាន់អតិថិជន និងយន្តការឆ្លើយតប ជាដើម។

សរុបសេចក្តីមក ក្រុមហ៊ុនគួរតែមានយន្តការការពារទុកជាមុន (proactive measures) ដើម្បីទប់ស្កាត់ការវាយប្រហារពីអ៊ិនធឺណិត។ ការត្រៀមខ្លួនជាស្រេច និងឆ្លើយតបយ៉ាងលឿនគឺសំខាន់ណាស់ក្នុងការជួយដល់ក្រុមហ៊ុនរបស់អ្នកស្រោចស្រង់ពីការវាយប្រហារប្រកបដោយប្រសិទ្ធិភាព៕



# Q&A

តើអ្វីទៅជា Cloud Storage?

តើសេវាកម្ម Cloud Storage ណាខ្លះ ដែលប្រើប្រាស់ដោយ ឥតគិតថ្លៃ?

## សំណួរ

ពេជ្រ រ៉ាឈីត
rachhitpich@gmail.com

ជម្រាបសួរ! ខ្ញុំបាទឈ្មោះ ពេជ្រ រ៉ាឈីត ជាប្រិយមិត្តអ្នកអានរបស់ទស្សនាវដ្ដីទីក្រុងពត៌មានវិទ្យា និងទីក្រុងទូរស័ព្ទ ហើយរាល់ថ្ងៃខ្ញុំរៀនឆ្នាំទី 1 នៃសាកលវិទ្យាល័យមួយនៅក្នុងរាជធានីភ្នំពេញ ផ្នែកព័ត៌មានវិទ្យា។ នៅពេលនេះប្អូនមានចម្ងល់មួយចំនួនចង់សួរខាងបងឱ្យជួយបកស្រាយនោះ គឺ 1- តើអ្វីទៅជា Cloud Storage? 2- តើសេវាកម្ម Cloud Storage ណាខ្លះដែលប្រើប្រាស់ដោយឥតគិតថ្លៃ? សូមបងជួយបង្ហាញដល់ប្អូនដោយអនុគ្រោះ និងសូមអរគុណចំពោះការចែករំលែកនេះ។

## ចម្លើយ

សួស្តី ប្អូន ពេជ្រ រ៉ាឈីត! ជាបឋម ទស្សនាវដ្ដីទីក្រុងពត៌មានវិទ្យា និងទីក្រុងទូរស័ព្ទ សូមអរគុណដល់ប្អូនក៏ដូចជាប្រិយមិត្តអ្នកអានផ្សេងទៀតដែលតែងតែគាំទ្រទស្សនាវដ្ដីរបស់យើងកន្លងមកនេះ ហើយក៏សូមអរគុណជាខ្លាំងចំពោះសំនួរប្អូនដែលបានសួរមកខាងបងដែលសំនួរនេះគឺពិតជាសំណួរដ៏ល្អ និងថ្មីៗក្តៅៗថែមទៀត។ ដូច្នេះដើម្បីធ្វើការដោះស្រាយនូវបញ្ហាដែលប្អូនបានជួបប្រទះដូចនេះយើងខ្ញុំដែលជាក្រុមការងារក្នុងទស្សនាវដ្ដីទីក្រុងពត៌មានវិទ្យា និងទីក្រុងទូរស័ព្ទសូមធ្វើការបង្ហាញប្រាប់លម្អិតនៅខាងក្រោមនេះអំពីសំណួរដែលប្អូនចង់ដឹង។



**មានចង្ងល់សូមទំនាក់ទំនងមកកាន់យើងខ្ញុំ**

facebook: It City Magazine

# សេវាកម្ម Cloud Storage Services ទាំងអស់ដែលលោកអ្នកអាចរក្សាទុកទិន្នន័យឥតគិតថ្លៃ

Cloud Storage គឺជាសេវាកម្មមួយប្រភេទដែលលោកអ្នកអាចប្រើប្រាស់ដោយឥតគិតថ្លៃសម្រាប់រក្សាទុកឯកសារទិន្នន័យរបស់អ្នកនៅលើអ៊ីនធើណិត ប៉ុន្តែសេវាកម្មខ្លះផ្តល់ទំហំអោយលោកអ្នកប្រើប្រាស់មិនច្រើននោះទេ។ ការប្រើប្រាស់ Cloud Storage មានភាពងាយស្រួល និងសុវត្ថិភាពបំផុតដោយសារតែលោកអ្នកមិនចាំបាច់ព្រួយបារម្ភនៅពេលដែលកុំព្យូទ័ររបស់លោកអ្នកបាត់បង់ ឬខូច Hard Disk លោកអ្នកអាចចូលទៅកាន់ Cloud Storage ដើម្បីទាញយកទិន្នន័យទាំងអស់នោះបានមកវិញគ្រប់ពេលវេលា។

ឥឡូវនេះ យើងនឹងនិយាយអំពីសេវាកម្ម Cloud Storage ដែលពេញនិយមបំផុតនៅក្នុងការប្រើប្រាស់សម្រាប់រក្សាទុកទិន្នន័យ។

## សេវាកម្ម Cloud Storage សម្រាប់ផ្ទុកទិន្នន័យធំ។

### Dropbox

Dropbox គឺជាសេវាកម្មមួយដ៏ពេញនិយមនៅក្នុង Cloud Storage ដោយសារតែវាដំណើរការលឿន និងមានភ្ជាប់ជាមួយកម្មវិធីសម្រាប់ប្រើប្រាស់នៅលើទូរស័ព្ទរួមទាំងកុំព្យូទ័ររបស់អ្នកផងដែរ។ ទំហំទិន្នន័យឥតគិតថ្លៃដែលលោកអ្នកអាចប្រើប្រាស់បានគឺ 2GB ប៉ុន្តែប្រសិនបើអ្នកណែនាំអោយមិត្តភក្តិប្រើប្រាស់សេវាកម្មនេះ អ្នកនឹងទទួលបានទិន្នន័យ 500MB បន្ថែមទៀតហើយអ្នកអាចទទួលបានទំហំប្រើប្រាស់ឥតគិតថ្លៃដល់ទៅ 16GB ។ លោកអ្នកអាចទិញទំហំបន្ថែម $10 ក្នុងមួយខែ ឬ $100 ក្នុងមួយឆ្នាំសម្រាប់ទំហំទិន្នន័យ 1TB។



### Box.com

Box គឺជាសេវាកម្ម Cloud Storage មួយទៀតពេញនិយមបំផុតបន្ទាប់ពី Dropbox ដោយសារតែសេវាកម្មនេះផ្តល់ទំហំធំសម្រាប់ផ្ទុកទិន្នន័យឥតគិតថ្លៃ។ Apps របស់វាអាចដំណើរការបាននៅលើស្មាតហ្វូន និងកុំព្យូទ័របានរួមទាំងការប្រើប្រាស់នៅលើ Box's API ផងដែរ។ លោកអ្នកអាចរក្សាទុកទិន្នន័យឥតគិតថ្លៃដល់ទៅ 10GB ហើយការអាប់ឡូតទិន្នន័យម្តងបានទំហំ 250MB ។ លោកអ្នកអាចចំណាយទឹកប្រាក់ $10 ក្នុងមួយខែសម្រាប់ទំហំផ្ទុកទិន្នន័យ 100GB។




### Google Drive

